ធនាគារជាតិនៃកម្ពុជា

ប្រាក់រៀល ស្ថិរភាព អភិវឌ្ឍន៍

# ព្រឹត្តិបត្រប្រចាំត្រីមាស




## លេខ ៥១

## ត្រីមាសទី ២ ឆ្នាំ២០១៧

ចេញផ្សាយតាមប្រកាសលេខ ធ៦-០១១-១២៣ ប្រ.ក ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១១

បោះពុម្ពផ្សាយដោយ

# ធនាគារជាតិ នៃ កម្ពុជា

| | | |
|---|---|---|
| អាសយដ្ឋាន | : | ២២-២៤ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា |
| ប្រអប់សំបុត្រ | : | ២៥ |
| ទូរស័ព្ទ | : | (៨៥៥) ២៣ ៧២២ ៥៦៣ |
| ទូរសារ | : | (៨៥៥) ២៣ ៤២៦ ១១៧ |
| គេហទំព័រ | : | www.nbc.org.kh |

*********

Published by

# National Bank of Cambodia

| | | |
|---|---|---|
| Address | : | 22-24 Preah Norodom Blvd.<br>Phnom Penh, Cambodia |
| P.O.BOX | : | 25 |
| Phone | : | (855) 23 722 563 |
| FAX | : | (855) 23 426 117 |
| Website | : | www.nbc.org.kh |

គណៈកម្មការត្រួតពិនិត្យ — Review Commission

- ឯកឧត្តម ថា យ៉ាវ ប្រធាន — H.E. Tha Yao, Chairman
- ឯកឧត្តម ស៊ុំ សន្និសិទ្ធ និពន្ធនាយក — H.E. Dr. Sum Sannisith, Chief Editor

# អារម្ភកថា



# ឯកឧត្តម ជា ចាន់តូ
# ទេសាភិបាលធនាគារជាតិនៃកម្ពុជា

*ប្រិយមិត្តអ្នកអានជាទីមេត្រី!*

ក្នុងត្រីមាសទី២ ឆ្នាំ២០១៧ នេះ ប្រជាជនកម្ពុជាមានក្តីសោមនស្សរីករាយដោយបានចូលរួមអបអរសាទរ និងប្រារព្ធពិធីបុណ្យជាតិសំខាន់ៗ រួមមាន ១/- បុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ ២/- បុណ្យចម្រើនព្រះជន្ម ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ៣/- ព្រះរាជពិធីច្រត់ព្រះនង្គ័ល និង ៤/- បុណ្យចម្រើនព្រះជន្មសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា នរោត្តមមុនីនាថ សីហនុ។

ក្នុងពេលវេលាដ៏រីករាយនេះ សេដ្ឋកិច្ចកម្ពុជា ក៏បន្តមានកំណើនរឹងមាំ គាំទ្រជាចម្បងដោយកំណើនខ្ពស់ក្នុងវិស័យសំណង់និងទេសចរណ៍ ស្របពេលសកម្មភាពនៃការនាំចេញសម្លៀកបំពាក់និងស្បែកជើងបន្តកើនឡើង។

វិស័យសំណង់មានកំណើនខ្ពស់គួរឱ្យកត់សម្គាល់ ឆ្លុះបញ្ចាំងតាមរយៈការនាំចូលសម្ភារសំណង់ គម្រោងសំណង់ និងតម្លៃគម្រោងដែលបានអនុញ្ញាត។ ការនាំចូលសម្ភារសំណង់មានកំណើនខ្ពស់ដល់ ៤៥,៥% ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន (២៥%)។ តម្លៃគម្រោងដែលបានអនុញ្ញាតមានកំណើន ៦៤% ដល់ ៣,៧ ប៊ីលានដុល្លារអាមេរិក បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន (២,២ ប៊ីលានដុល្លារអាមេរិក) ហើយចំនួនគម្រោងដែលបានអនុញ្ញាតមានកំណើនប្រមាណ ៤% ដល់ ៧៣៧ គម្រោង។ ចំពោះវិស័យទេសចរណ៍ ចំនួនភ្ញៀវទេសចរចូលមកកម្ពុជាបានកើនឡើងក្នុងអត្រាពីរខ្ទង់ ១៣,៩% ជាអត្រាកំណើនខ្ពស់បំផុតចាប់ពីឆ្នាំ២០១៤មក ដោយអត្រាកំណើនមធ្យមក្នុងរយៈពេលបីឆ្នាំចុងក្រោយមានកម្រិតត្រឹម ៣,៥% ប៉ុណ្ណោះ។ កំណើនខ្ពស់ក្នុងវិស័យនេះ រួមចំណែកដោយកំណើនខ្លាំងក្លារបស់ទីផ្សារទេសចរណ៍ចិន ដែលមានកំណើនជាមធ្យមប្រមាណ ៦០% ក្នុងត្រីមាសទី២ ឆ្នាំ២០១៧នេះ ដែលអាចបណ្តាលមកពីប្រសិទ្ធភាពនៃគោលនយោបាយទាក់ទាញទេសចរចិន និងការបង្កើនការហោះហើរត្រង់មកកម្ពុជា។

ដោយឡែក ការនាំចេញរបស់កម្ពុជាមានស្ថានភាពប្រសើរជាងមុន។ ការនាំចេញទំនិញសរុបបានកើនឡើង ២៧% ជាកំណើនខ្ពស់ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ ក្នុងនោះការនាំចេញតាមប្រព័ន្ធអនុគ្រោះពន្ធ (ដែលមានសមាមាត្រប្រមាណ ៩៧% នៃការនាំចេញសរុប) កើនរហូតដល់ ២៦% ធៀបនឹង ១២% កាលពីគ្រាដូចគ្នាឆ្នាំមុន។ ការនាំចេញសម្លៀកបំពាក់ មានកំណើនរហូតដល់ ១១,៦% ធៀបនឹងកំណើនត្រឹម ៦,៥% ក្នុងគ្រាដូចគ្នាឆ្នាំមុន ដោយសារកំណើនតម្រូវការពីតំបន់អឺរ៉ុប សហរដ្ឋ-អាមេរិក និងប្រទេសជប៉ុន ដែលជាទីផ្សារនាំចេញធំរបស់កម្ពុជា។ ការនាំចេញស្បែកជើងដែលជាការនាំចេញធំទីពីរក្នុងវិស័យកាត់ដេរបន្ទាប់ពីសម្លៀកបំពាក់ (មានចំណែកប្រមាណ ៩% នៃការនាំចេញសរុបតាមប្រព័ន្ធអនុគ្រោះពន្ធ) មានកំណើនខ្ពស់ដល់ ២៧% ធៀបនឹងគ្រាដូចគ្នា ឆ្នាំមុន (១៤%)។

ទន្ទឹមនេះ វិស័យធនាគារកម្ពុជា ដែលមានតួនាទីស្នូលក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិបានបន្តអភិវឌ្ឍប្រកបដោយភាពរឹងមាំ។ ការរីកចម្រើននេះ ឆ្លុះបញ្ចាំងតាមរយៈការកើនឡើងជាលំដាប់នៃទ្រព្យសកម្មវិស័យធនាគារ ប្រាក់បញ្ញើ និងឥណទាន ដោយសារការកើនឡើងជំនឿទុកចិត្តរបស់សាធារណជនមកលើប្រសិទ្ធភាពនៃវិស័យធនាគារកម្ពុជា។ ទ្រព្យសកម្មវិស័យធនាគារបានកើនឡើងដល់ ១២៤ ទ្រីលានរៀលសមាមាត្រនឹង ១៣៧% នៃផ.ស.ស ស្របពេលដែលទំហំឥណទាននិងប្រាក់បញ្ញើក្នុងវិស័យនេះ កើនដល់ ៧៣,៧ និង ៦៣ ទ្រីលានរៀល រៀងគ្នា ឬសមាមាត្រនឹង ៨១% និង ៧០% នៃផ.ស.ស រៀងគ្នា។

សរុបមក លទ្ធផលដ៏ល្អប្រសើរទាំងនេះ បានស្តែងឱ្យឃើញពីជោគជ័យនៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងធនាគារជាតិនៃកម្ពុជា ក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងការអភិវឌ្ឍវិស័យធនាគារកម្ពុជា ដើម្បីគាំទ្រការរីកចម្រើននៃសេដ្ឋកិច្ចប្រកបដោយចីរភាព និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។

ដូចទៅនឹងព្រឹត្តិបត្រមុនដែរៗ នៅព្រឹត្តិបត្រប្រចាំត្រីមាសទី២ ឆ្នាំ២០១៧ នេះ មានរាប់បញ្ចូលព័ត៌មានអំពីសកម្មភាពរបស់ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ការចេញប្រកាសថ្មីៗ និងស្ថានភាពបច្ចុប្បន្នរបស់ប្រព័ន្ធធនាគារកម្ពុជា។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា និងភាគីពាក់ព័ន្ធទាំងអស់ ដែលបានខិតខំប្រឹងប្រែងរួមចំណែកអភិវឌ្ឍវិស័យធនាគារ សំដៅគាំទ្រនិងជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន។

ខ្ញុំសូមប្រសិទ្ធពរជ័យ សិរីសួស្តី ជូនដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រិយមិត្តអ្នកអានទាំងអស់ សូមប្រកបតែសេចក្តីសុខ ទទួលបានជោគជ័យគ្រប់ភារកិច្ច និងជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**

# មាតិកា

ទំព័រ


- អារម្ភកថា ........................................ i-ii
- ប្រកាស ស្ដីពីការកែសម្រួលចំណុច ៥ ប្រការ ២ នៃប្រកាសស្ដីពីការចេញផ្សាយមូលបត្រអាចជួញដូរបានដោយធនាគារជាតិនៃកម្ពុជា (ជាភាសាខ្មែរ)........................................ ១
- ប្រកាស ស្ដីពីការគ្រប់គ្រងគ្រឹះស្ថានផ្ដល់សេវាទូទាត់សងប្រាក់ (ជាភាសាខ្មែរ)........................ ៣
- សុន្ទរកថា ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៧ របស់ធនាគារជាតិនៃកម្ពុជា (ជាភាសាខ្មែរ)........................................ ១៩
- សុន្ទរកថា ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ថ្លែងក្នុងឱកាសបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៧ របស់ធនាគារជាតិនៃកម្ពុជា (ជាភាសាខ្មែរ)........................................ ២៤
- អត្ថបទស្រាវជ្រាវ ស្ដីពីទុនបម្រុងអន្តរជាតិ (ជាភាសាខ្មែរ)........................................ ៣០
- តារាងអត្រាប្ដូរប្រាក់ប្រចាំខែ (ភាសាខ្មែរនិងអង់គ្លេស) ........................................ ៣៦
- តារាងអត្រាការប្រាក់លើប្រាក់បញ្ញើ (ភាសាខ្មែរនិងអង់គ្លេស) ........................................ ៣៨
- តារាងអត្រាការប្រាក់លើប្រាក់កម្ចី (ភាសាខ្មែរនិងអង់គ្លេស)........................................ ៤០
- ចំនួនការិយាល័យ និងតំបន់ប្រតិបត្តិការនៃធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជា (ភាសាខ្មែរ និងអង់គ្លេស)........................................ ៤២
- ប្រព័ន្ធធនាគារកម្ពុជា (ភាសាខ្មែរនិងអង់គ្លេស) ........................................ ៥០
- រូបថតសកម្មភាពថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា........................................ ៥២-៦៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៥-០១៧-១៤៨ ប្រ.ក

# ប្រកាស
# ស្តីពី
# ការកែសម្រួលចំណុច ៥ ប្រការ ២ នៃប្រកាសស្តីពី ការចេញផ្សាយមូលបត្រអាចជួញដូរបានដោយធនាគារជាតិនៃកម្ពុជា

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤១៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការតែងតាំង ឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- យោងប្រកាសលេខ ធ៨-៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ៥-០៩-២២៩ ប្រ.ក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩ ស្តីពីការដាក់ឱ្យអនុវត្តកិច្ចសន្យាមេសម្រាប់ប្រតិបត្តិការទទួលទិញវិញ ដើម្បីធានាដល់ប្រតិបត្តិការអន្តរធនាគារនៅក្នុងទីផ្សាររូបិយវត្ថុ
- យោងតាមការចាំបាច់របស់អគ្គនាយកដ្ឋានបច្ចេកទេស

## សម្រេច

**ប្រការ មួយ.-**

កែសម្រួលចំណុច ៥ ប្រការ ២ នៃប្រកាសលេខ ធ៥-០១០-១៨៣ ប្រ-ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពីការចេញផ្សាយមូលបត្រអាចជួញដូរបានដោយធនាគារជាតិនៃកម្ពុជា មានដូចខាងក្រោម ៖

**ប្រការ ២ថ្មី.~**

ចំណុច ៥ ថ្មី: មូលបត្រអាចជួញដូរបានមានឥណប្រតិទានគិតជាថ្ងៃលើមូលដ្ឋានសប្តាហ៍ ៧ថ្ងៃ ១៤ថ្ងៃ ២៨ថ្ងៃ ៩១ថ្ងៃ ១៨២ថ្ងៃ និង ៣៦៤ថ្ងៃ។ ឥណប្រតិទានអាចនឹងត្រូវបានកែតម្រូវដោយធនាគារជាតិនៃកម្ពុជានៅថ្ងៃបញ្ចាទិញ ក្នុងករណីដែលឥណប្រតិទាននេះត្រូវចំថ្ងៃឈប់សម្រាកការងារដែលកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា។

**ប្រកាស ពីរ.~**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន-អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗ ខ្លួន ។

**ប្រការ បី.~**

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ២០១៧

**ទេសាភិបាល**

**ជា ចាន់តូ**

**កន្លែងទទួល:**
-ដូចប្រការពីរ "**ដើម្បីអនុវត្ត**"
-កាលប្បវត្តិ
-ឯកសារ

**ចម្លងជូន**
-សមាជិកក្រុមប្រឹក្សាភិបាល
-ទីស្តីការគណៈរដ្ឋមន្ត្រី "**ដើម្បីជ្រាបជាព័ត៌មាន**"
-នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
"**ដើម្បីចុះផ្សាយក្នុងរាជកិច្ច**"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧-០១៧-១៦១ ប្រ.ក

# ប្រកាស
# ស្តីពី
# ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤១៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជាជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣០ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់
- យោងប្រកាសលេខ ធ៨-៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជានិងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ៩-០១០-១៥១ ប្រ.ក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០ ស្តីពី អ្នកដំណើរការតតិយភាគី
- យោងស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ ។

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១**.-

ប្រកាសនេះ មានគោលបំណងគ្រប់គ្រងនិងកំណត់នីតិវិធីនៃការស្នើសុំអាជ្ញាប័ណ្ណចំពោះនីតិបុគ្គលទាំងឡាយណាដែលផ្តល់សេវាទូទាត់សងប្រាក់ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២**.-

ប្រកាសនេះ រៀបចំឡើងសម្រាប់គោលដៅដូចខាងក្រោម ៖

១- ធានាសុវត្ថិភាព និងភាពរឹងមាំនៃសេវាទូទាត់សងប្រាក់

២- ជំរុញការប្រកួតប្រជែងដោយស្មោះត្រង់ និងលើកកម្ពស់គំនិតច្នៃប្រឌិត និង

៣- ផ្តល់ជំនឿទុកចិត្តដល់សាធារណៈជនលើសេវាទូទាត់សងប្រាក់ ។

**ប្រការ ៣**.-

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះនីតិបុគ្គលទាំងឡាយណាដែលផ្តល់សេវាទូទាត់សងប្រាក់ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលស្ថិតនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៤**.-

ការផ្តល់សេវាក្នុងករណីដូចខាងក្រោម មិនស្ថិតនៅក្រោមវិសាលភាពនៃប្រកាសនេះទេ ៖

១- ការផ្តល់ប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ទ្រទ្រង់សេវាកម្មទូទាត់សងប្រាក់ ដោយមិនពាក់ព័ន្ធក្នុងការរក្សាទុកមូលនិធិ ការរក្សាទុកនិងដំណើរការទិន្នន័យ បរធនបាលកិច្ច និងការរក្សាការសម្ងាត់ ការបញ្ជាក់អត្តសញ្ញាណនិងទិន្នន័យ ប្រព័ន្ធព័ត៌មានវិទ្យានិងទូរគមនាគមន៍ ការថែរក្សាទីតាំង និងឧបករណ៍សម្រាប់សេវាទូទាត់សងប្រាក់ ។ ចំពោះប្រតិបត្តិការទូទាត់សងប្រាក់ដែលប្រើទីតាំងគ្រឹះស្ថានធនាគារសម្រាប់តែប្រតិបត្តិការផ្ទេរប្រាក់ និងទទួលបញ្ញាផ្ទេរប្រាក់ ត្រូវស្ថិតក្រោមវិសាលភាពប្រកាសស្តីពី " អ្នកដំណើរការតតិយភាគី " ។

២- សេវាផ្អែកលើឧបករណ៍ទូទាត់ជាក់លាក់ ដែលអាចប្រើប្រាស់បាននៅក្នុងកម្រិតកំណត់ណាមួយ និងឧបករណ៍ដែលអាចទូទាត់ទំនិញ ឬសេវាកម្មតែនៅក្នុងទីតាំងរបស់គ្រឹះស្ថានចេញផ្សាយ ឬនៅក្នុងតែបណ្តាញទីតាំងរបស់គ្រឹះស្ថានដែលចេញផ្សាយ ។

**ប្រការ ៥**.-

ពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះត្រូវបានកំណត់ដូចខាងក្រោម ៖

- **អ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់** សំដៅលើរូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រើប្រាស់សេវាទូទាត់សងប្រាក់ដូចជា អ្នកសងប្រាក់ ឬអ្នកទទួលប្រាក់ ឬទាំងពីរ ។

- **ប្រតិបត្តិការទូទាត់សងប្រាក់** សំដៅលើសកម្មភាពដែលធ្វើឡើងដោយអ្នកសងប្រាក់ អ្នកតំណាងអ្នកសងប្រាក់ ឬអ្នកទទួលប្រាក់ ដើម្បីធ្វើប្រតិបត្តិការ ដាក់ប្រាក់ ផ្ទេរប្រាក់ ឬដកប្រាក់ ។
- **មូលនិធិ** សំដៅលើធនបត្រ កាស និងរូបិយវត្ថុអេឡិចត្រូនិក ។
- **ឧបករណ៍ទូទាត់សងប្រាក់** សំដៅលើឧបករណ៍ដែលអាចឱ្យអ្នកកាន់ ឬអ្នកប្រើប្រាស់ធ្វើប្រតិបត្តិការទូទាត់សងប្រាក់បានតាមរយៈឧបករណ៍នោះ ។
- **រូបិយវត្ថុអេឡិចត្រូនិក** សំដៅលើតម្លៃជារូបិយវត្ថុតំណាងឲ្យបំណុលចំពោះអ្នកចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិក ចេញផ្សាយនៅពេលទទួលបានមូលនិធិផ្ទុកតម្លៃជាអេឡិចត្រូនិកសម្រាប់ប្រើប្រាស់ក្នុងគោលបំណងទូទាត់សងប្រាក់ និងទទួលស្គាល់ជាឧបករណ៍ទូទាត់សងប្រាក់ដោយរូបវន្តបុគ្គល និងនីតិបុគ្គលក្រៅពីអ្នកចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិក ។
- **អ្នកចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិក** សំដៅដល់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ដែលបានទទួលអាជ្ញាប័ណ្ណក្នុងការចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិកនៅក្រោមប្រកាសនេះ ។
- **ប្រតិបត្តិការផ្ទេរឥណពន្ធដោយផ្ទាល់** សំដៅដល់សេវាទូទាត់សងប្រាក់ដែលផ្តើមប្រតិបត្តិការឡើងដោយអ្នកទទួលប្រាក់បញ្ជាទៅគ្រឹះស្ថានផ្តល់សេវាទូទាត់របស់ខ្លួន ឬទៅគ្រឹះស្ថានផ្តល់សេវាទូទាត់របស់អ្នកសងប្រាក់ ឱ្យផ្ទេរប្រាក់ចេញពីគណនីរបស់អ្នកសងប្រាក់មកគណនីរបស់អ្នកទទួលប្រាក់ ដោយមានការព្រមព្រៀងគ្នាជាមុនរវាងអ្នកសងប្រាក់ និងអ្នកទទួលប្រាក់ ។
- **ប្រតិបត្តិការផ្ទេរឥណទាន** សំដៅដល់សេវាទូទាត់សងប្រាក់លើប្រតិបត្តិការទូទាត់សងប្រាក់មួយ ឬ ច្រើនដែលអ្នកសងប្រាក់បញ្ជាទៅគ្រឹះស្ថានផ្តល់សេវាទូទាត់របស់ខ្លួនឱ្យផ្ទេរប្រាក់ចេញពីគណនីរបស់ខ្លួនទៅគណនីរបស់អ្នកទទួលប្រាក់ ។
- **គណនីទូទាត់សងប្រាក់** សំដៅដល់គណនីដែលបើកដោយអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់ និងប្រើសម្រាប់ប្រតិបត្តិការទូទាត់សងប្រាក់ ។
- **សេវាផ្តើមការទូទាត់សងប្រាក់** សំដៅដល់សេវាដែលផ្តើមបញ្ជាទូទាត់តាមសំណើអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់តាមរយៈគណនីធនាគារ ឬគណនីទូទាត់សងប្រាក់ ដែលរក្សាទុកជាមួយនឹងគ្រឹះស្ថានធនាគារ ឬគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់មួយទៀត ។
- **គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់** សំដៅលើគ្រឹះស្ថានទាំងឡាយណាដែលទទួលបានអាជ្ញាប័ណ្ណក្នុងការផ្តល់សេវាទូទាត់សងប្រាក់អនុលោមតាមប្រកាសនេះ ។

- **បញ្ជាផ្ទេរប្រាក់ជាប្រចាំ** សំដៅដល់បញ្ជាផ្ទេរប្រាក់ធ្វើឡើងដោយអ្នកទូទាត់សងប្រាក់ផ្ដល់ឱ្យធនាគាររបស់ខ្លួនធ្វើការទូទាត់សងប្រាក់ជាប្រចាំ នូវចំនួនទឹកប្រាក់កំណត់ទៅគណនីអ្នកទទួលប្រាក់ ។
- **គណនីអាណត្តិព្យាបាល** សំដៅដល់គណនីដែលបើកដោយអ្នកចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិក នៅពេលទទួលសាច់ប្រាក់ពីអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់ រក្សាទុកនៅក្នុងធនាគារអាណត្តិព្យាបាលមួយ ឬច្រើន ក្នុងគោលបំណងធ្វើប្រតិបត្តិការទូទាត់សងប្រាក់តែមួយគត់ ដែលបញ្ជាដោយអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់ និងមិនត្រូវប្រើប្រាស់សម្រាប់ប្រតិបត្តិការប្រចាំថ្ងៃរបស់អ្នកចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិកឡើយ ។
- **ភ្នាក់ងារ** សំដៅលើរូបវន្តបុគ្គល ឬនីតិបុគ្គលដែលផ្ដល់សេវាទូទាត់សងប្រាក់ក្នុងនាមគ្រឹះស្ថានផ្ដល់សេវាទូទាត់សងប្រាក់ ។
- **ការផ្ដល់សេវាជំនួស** សំដៅដល់ការប្រគល់សេវាមួយផ្នែក ឬច្រើនផ្នែក ដែលបានព្រមព្រៀងគ្នាជាមួយបុគ្គល ឬគ្រឹះស្ថានមួយផ្សេងទៀត ដើម្បីធ្វើសេវានោះជំនួសខ្លួន ។
- **ការផ្ទេរប្រាក់** សំដៅដល់សកម្មភាពផ្ញើប្រាក់ពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត (ដោយពុំចាំបាច់មានគណនីនៅធនាគារ) តាមរយៈគ្រឹះស្ថានផ្ដល់សេវាទូទាត់សងប្រាក់ ។

## ជំពូកទី ២
## នីតិវិធីនៃការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ

### ប្រការ ៦.-

សេវាទូទាត់សងប្រាក់ត្រូវបានកំណត់ដូចខាងក្រោម ៖

១- សេវាដែលផ្ដល់លទ្ធភាពឱ្យមានការដកប្រាក់ និងដាក់ប្រាក់ក្នុងគណនីទូទាត់សងប្រាក់ និងប្រតិបត្តិការទាំងឡាយណាដែលដំណើរការតាមរយៈគណនីទូទាត់សងប្រាក់នោះ ។

២- ធ្វើប្រតិបត្តិការទូទាត់សងប្រាក់ រួមទាំងការផ្ទេរប្រាក់ពីគណនីទូទាត់សងប្រាក់មួយទៅគណនីទូទាត់សងប្រាក់មួយទៀត ដែលមាននៅជាមួយគ្រឹះស្ថានផ្ដល់សេវាទូទាត់សងប្រាក់មួយ ឬជាមួយគ្រឹះស្ថានផ្ដល់សេវាទូទាត់សងប្រាក់ផ្សេងទៀត ៖

ក) ប្រតិបត្តិការផ្ទេរឥណពន្ធដោយផ្ទាល់

ខ) ប្រតិបត្តិការទូទាត់សងប្រាក់តាមរយៈប័ណ្ណទូទាត់ ឬឧបករណ៍ទូទាត់ប្រហាក់ប្រហែល

គ) ប្រតិបត្តិការផ្ទេរឥណទាន រួមទាំងបញ្ជាផ្ទេរជាប្រចាំ ។

៣- ធ្វើប្រតិបត្តិការទូទាត់សងប្រាក់ ដែលមូលនិធិត្រូវបានផ្តល់ជាឥណទានទៅឱ្យអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់ ៖

ក) ប្រតិបត្តិការផ្ទេរឥណពន្ធដោយផ្ទាល់

ខ) ប្រតិបត្តិការទូទាត់សងប្រាក់តាមរយៈប័ណ្ណទូទាត់ ឬឧបករណ៍ទូទាត់ប្រហាក់ប្រហែល

គ) ប្រតិបត្តិការផ្ទេរឥណទាន រួមទាំងបញ្ជាផ្ទេរជាប្រចាំ ។

៤- ចេញផ្សាយឧបករណ៍ទូទាត់ រួមទាំងការចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិក និង/ឬ ទទួលយកប្រតិបត្តិការទូទាត់

៥- ការផ្ទេរប្រាក់នៅក្នុងប្រទេសនិងក្រៅប្រទេស

៦- សេវាផ្ញើមការទូទាត់សងប្រាក់

៧- សេវាទូទាត់សងប្រាក់ផ្សេងៗទៀតដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៧.-**

១- បន្ថែមលើប្រតិបត្តិការដែលមានចែងក្នុងប្រការ ៦ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់អាចធ្វើសកម្មភាពដូចខាងក្រោម បន្ទាប់ពីមានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ៖

ក) ប្រតិបត្តិការដែលមានជាប់ពាក់ព័ន្ធជាមួយសេវាកម្មស្នូល ដូចជា ដំណើរការប្រតិបត្តិការទូទាត់សងប្រាក់ សេវាប្តូរប្រាក់ សេវារក្សាទុក និងបំលែងទិន្នន័យ

ខ) បើកគណនីជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

គ) ការចូលរួមជាសមាជិកនៅក្នុងប្រព័ន្ធជាត់ទាត់និងទូទាត់សងប្រាក់

ឃ) សកម្មភាពអាជីវកម្មផ្សេងទៀត ដែលស្ថិតនៅក្រោមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

២- ក្នុងករណីដែលគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ធ្វើសកម្មភាពអាជីវកម្មផ្សេងទៀត ធនាគារជាតិនៃកម្ពុជា តម្រូវឱ្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់បង្កើតអង្គភាពដោយឡែក សម្រាប់ប្រតិបត្តិការទូទាត់សងប្រាក់ ប្រសិនបើសកម្មភាពអាជីវកម្មផ្សេងទៀតបានប៉ះពាល់ ឬអាចធ្វើឱ្យប៉ះពាល់ដល់ភាពរឹងមាំផ្នែកហិរញ្ញវត្ថុ ឬការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ របស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ។

៣- គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់អាចបើកគណនីទូទាត់សងប្រាក់ ប្រើប្រាស់សម្រាប់ប្រតិបត្តិការទូទាត់សងប្រាក់ប៉ុណ្ណោះ ។ មូលនិធិដែលគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ទទួលបាន មិនចាត់ទុកថាជាប្រាក់បញ្ញើនោះទេ ។

៤- គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ អាចផ្តល់ឥណទានពាក់ព័ន្ធសេវាទូទាត់សងប្រាក់បាន ក្នុងករណីដូចខាងក្រោម ៖

ក) ឥណទានជាសេវាកម្មបន្ថែម និងផ្តល់ឱ្យសម្រាប់ប្រតិបត្តិការទូទាត់សងប្រាក់ប៉ុណ្ណោះ

ខ) ឥណទានផ្តល់ឱ្យសម្រាប់ប្រតិបត្តិការទូទាត់ ត្រូវទូទាត់សងក្នុងរយៈពេលយ៉ាងយូរបំផុត ១៨០ ថ្ងៃ (មួយរយប៉ែតសិបថ្ងៃ)

គ) មូលនិធិដែលទទួលពីអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់ សម្រាប់ប្រតិបត្តិការទូទាត់សងប្រាក់ មិនត្រូវយកមកប្រើប្រាស់សម្រាប់ផ្តល់ឥណទានទេ

ឃ) មូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ត្រូវមានកម្រិតសមស្របជាមួយទំហំឥណទានដែលបានផ្តល់ ។

## ប្រការ ៨.-

នីតិបុគ្គលដែលមានបំណងផ្តល់សេវាទូទាត់សងប្រាក់ ត្រូវស្នើសុំអាជ្ញាប័ណ្ណជាមុនពីធនាគារជាតិនៃកម្ពុជា ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលមានបំណងផ្តល់សេវាទូទាត់សងប្រាក់រួមទាំងការចេញផ្សាយឧបករណ៍ទូទាត់សងប្រាក់ ត្រូវស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា ។

## ប្រការ ៩-

នីតិបុគ្គលដែលមានបំណងផ្តល់សេវាទូទាត់សងប្រាក់ ត្រូវដាក់ពាក្យស្នើសុំមកធនាគារជាតិនៃកម្ពុជា ដោយបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

១- ការពិពណ៌នាជាលាយលក្ខណ៍អក្សរអំពីប្រភេទនៃសេវាទូទាត់សងប្រាក់ ដែលនឹងត្រូវធ្វើប្រតិបត្តិការ

២- ផែនការអាជីវកម្មដែលរួមបញ្ចូលទាំងការប៉ាន់ស្មានអំពីគម្រោងថវិកាសម្រាប់រយៈពេល ៣ ឆ្នាំ (បីឆ្នាំ) ដំបូង ដែលបង្ហាញអំពីលទ្ធភាពប្រើប្រាស់ប្រព័ន្ធ ធនធាន និងនីតិវិធីសមស្រប ដើម្បីធានាភាពរឹងមាំនៃដំណើរការអាជីវកម្ម

៣- ភស្តុតាងអំពីភាពគ្រប់គ្រាន់នៃដើមទុន

៤- ការពិពណ៌នាអំពីនីតិវិធីក្នុងការរក្សាសុវត្ថិភាពមូលនិធិ

៥- ការពិពណ៌នាអំពីការរៀបចំអភិបាលកិច្ច និងយន្តការត្រួតពិនិត្យផ្ទៃក្នុង រួមមានទម្រង់បែបបទរដ្ឋបាល ការគ្រប់គ្រងហានិភ័យ និងនីតិវិធីគណនេយ្យ ដែលមានភាពសមស្របរឹងមាំ និងគ្រប់គ្រាន់

៦- ការពិពណ៌នាអំពីនីតិវិធីក្នុងការដោះស្រាយវិវាទរបស់អតិថិជន ព្រមទាំងយន្តការក្នុងការត្រួតពិនិត្យ និងតាមដានឧបទ្ទវហេតុដែលកើតឡើង

៧- ការពិពណ៌នាអំពីនីតិវិធីសម្រាប់ចងក្រងឯកសារ ពិនិត្យ តាមដាន និងដាក់កម្រិតចំពោះការប្រើប្រាស់ទិន្នន័យសំខាន់ៗ

៨- ការពិពណ៌នាអំពីផែនការនិរន្តរភាពអាជីវកម្ម រួមមានការកំណត់អត្តសញ្ញាណប្រតិបត្តិការស្នូល ផែនការយថាភាព និងនីតិវិធីសម្រាប់ធ្វើការសាកល្បងជាប្រចាំ

៩- ការពិពណ៌នាអំពីគោលការណ៍ និងវិធីសាស្ត្រក្នុងការប្រមូលទិន្នន័យពាក់ព័ន្ធនឹងប្រតិបត្តិការ និងការក្លែងបន្លំ

១០- គោលនយោបាយសុវត្ថិភាព ដែលរួមមានការវាយតម្លៃលម្អិតអំពីហានិភ័យពាក់ព័ន្ធនឹងសេវាទូទាត់សងប្រាក់រួមទាំងការក្លែងបន្លំ ការប្រើប្រាស់ខុសច្បាប់នៃទិន្នន័យផ្ទាល់ខ្លួន និងទិន្នន័យសំខាន់ៗ ព្រមជាមួយការពិពណ៌នាអំពីវិធានការគ្រប់គ្រងសុវត្ថិភាព និងការកាត់បន្ថយហានិភ័យទាំងនោះ

១១- ការពិពណ៌នាអំពីការរៀបចំយន្តការ និងកាតព្វកិច្ចដើម្បីអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

១២- ការពិពណ៌នាអំពីរចនាសម្ព័ន្ធចាត់តាំង រួមទាំងការប្រើប្រាស់ភ្នាក់ងារនិងសាខា ការត្រួត-ពិនិត្យភ្នាក់ងារ ការផ្តល់សេវាជំនួស និងការចូលរួមជាមួយប្រព័ន្ធផាត់ទាត់និងទូទាត់សងប្រាក់

១៣- ការពិពណ៌នាអំពីអត្តសញ្ញាណនិងគុណវុឌ្ឍិរបស់ភាគទុនិក ទំហំនៃការកាន់កាប់ភាគហ៊ុន និងភស្តុតាងបញ្ជាក់អំពីភាពសមស្រប ដើម្បីធានានូវភាពរឹងមាំនិងការគ្រប់គ្រងដោយប្រុងប្រយ័ត្ន

១៤- ការពិពណ៌នាអំពីអត្តសញ្ញាណក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង ព្រមទាំងភស្តុតាងបញ្ជាក់អំពីកេរ្តិ៍ឈ្មោះ ចំណេះដឹង និងបទពិសោធន៍គ្រប់គ្រាន់ក្នុងការផ្តល់សេវាទូទាត់សងប្រាក់

១៥- ព័ត៌មានទាក់ទងនឹងអត្តសញ្ញាណនៃសវនករ និងស្ទងការគណនេយ្យឯករាជ្យប្រតិស្រុតិ

១៦- ឯកសារគតិយុត្ត លក្ខន្តិកៈ និងឯកសារបង្កើតផ្សេងៗទៀត

១៧- កំណត់ពីអាសយដ្ឋាននៃស្នាក់ការកណ្តាលរបស់ក្រុមហ៊ុន ។

**ប្រការ ១០.-**

១- ពាក្យស្នើសុំអាជ្ញាប័ណ្ណត្រូវភ្ជាប់ជាមួយសោហ៊ុយសាកសួរព័ត៌មានចំនួន ៥០០.០០០ រៀល (ប្រាំរយពាន់រៀល) និងសិក្សាសំណុំលិខិតចំនួន ២.០០០.០០០ រៀល (ពីរលានរៀល) ។

២- គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវបង់សោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំ ចំនួន ២០.០០០.០០០ រៀល (ម្ភៃលានរៀល) អោយបានត្រឹមថ្ងៃទី១៥ នៃខែមករា ។

៣- ចំពោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ដែលស្នើសុំអាជ្ញាប័ណ្ណនៅក្នុងឆ្នាំ សោហ៊ុយអាជ្ញាប័ណ្ណ នឹងត្រូវបានគណនាតាមសមាមាត្រនៃរយៈពេលដែលនៅសល់រហូតដល់ដំណាច់ឆ្នាំ ។

## ប្រការ ១១.-

ធនាគារជាតិនៃកម្ពុជា នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការសម្រេចរបស់ខ្លួនក្នុងរយៈពេល ៦ ខែ (ប្រាំមួយខែ) ចាប់ពីកាលបរិច្ឆេទទទួលពាក្យស្នើសុំអាជ្ញាប័ណ្ណ រួមទាំង ឯកសារពាក់ព័ន្ធផ្សេងៗពេញលេញ ។ ប្រសិនបើចាំបាច់ ធនាគារជាតិនៃកម្ពុជាអាចពន្យាររយៈពេលនៃការសិក្សាពាក្យស្នើសុំ ។ ធនាគារជាតិនៃកម្ពុជា នឹងដាក់ចេញនូវលក្ខខណ្ឌ និងរយៈពេលនៃការអនុវត្តលិខិតអនុញ្ញាតជាគោលការណ៍ ។ ក្នុងករណីអ្នកដាក់ពាក្យស្នើសុំពុំបានអនុវត្តតាមលក្ខខណ្ឌ និងរយៈពេលកំណត់ខាងលើ លិខិតអនុញ្ញាតជាគោលការណ៍ត្រូវចាត់ទុកជាមោឃៈ លើកលែងតែមានការស្នើសុំពន្យាពេល និងមានការយល់ព្រមពីធនាគារជាតិនៃកម្ពុជា ។ ធនាគារជាតិនៃកម្ពុជា នឹងផ្តល់អាជ្ញាប័ណ្ណជាផ្លូវការដល់អ្នកដាក់ពាក្យស្នើសុំ បន្ទាប់ពីពិនិត្យឃើញថារាល់លក្ខខណ្ឌដែលមានចែងក្នុងលិខិតអនុញ្ញាតជាគោលការណ៍ និងសំណុំបែបបទត្រូវបានបំពេញសព្វគ្រប់ ។

## ប្រការ ១២.-

អាជ្ញាប័ណ្ណមានសុពលភាពសម្រាប់រយៈពេល ៦ ឆ្នាំ (ប្រាំមួយឆ្នាំ) ។ អាជ្ញាប័ណ្ណនេះអាចស្នើសុំបន្តជាថ្មីបាន លុះត្រាតែគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ធ្វើសកម្មភាពស្របតាមច្បាប់ និងបទប្បញ្ញត្តិនានា ហើយរាល់ការប្រព្រឹត្តល្មើសច្បាប់និងបទបញ្ជាប្រុងប្រយ័ត្ន ប្រសិនបើមានត្រូវបានដោះស្រាយ ។

ពាក្យស្នើសុំបន្តអាជ្ញាប័ណ្ណ ត្រូវដាក់ជូនធនាគារជាតិនៃកម្ពុជាយ៉ាងយូរបំផុត ៣ ខែ (បីខែ) មុនពេលអាជ្ញាប័ណ្ណផុតសុពលភាព ។ ក្នុងករណីដែលការស្នើសុំនេះមានបញ្ចូលសេវាថ្មី ឬមានវិធីសាស្ត្រខុសគ្នាច្រើនចំពោះការផ្តល់សេវាដូចគ្នា ត្រូវចាត់ទុកថាជាការស្នើសុំអាជ្ញាប័ណ្ណថ្មី ។

ក្នុងករណីមិនបានដាក់ពាក្យស្នើសុំបន្តតាមកាលកំណត់ខាងលើ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ត្រូវទទួលរងការផាកពិន័យជាប្រាក់ចំនួន ១.០០០.០០០ រៀល (មួយលានរៀល) ក្នុងមួយថ្ងៃរហូតដល់ថ្ងៃបានដាក់ពាក្យស្នើសុំ ។

ក្នុងករណីមិនព្រមមកដាក់ពាក្យស្នើសុំបន្តទៀត គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់នឹងត្រូវទទួលរងការផាកពិន័យធ្ងន់ធ្ងរឡើង ដែលអាចនឹងឈានដល់ការព្យួរ ឬដកហូតអាជ្ញាប័ណ្ណតែម្តង ។

## ជំពូកទី ៣
## ដើមទុនអប្បបរមា និងវិធានការប្រុងប្រយ័ត្ន

**ប្រការ ១៣.-**

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវមានដើមទុនចុះបញ្ជីអប្បបរមាសម្រាប់ធ្វើប្រតិបត្តិការចំនួន ៨.០០០.០០០.០០០ រៀល (ប្រាំបីពាន់លានរៀល) ជាសាច់ប្រាក់ ។

ធនាគារជាតិនៃកម្ពុជាអាចកែប្រែកម្រិតដើមទុនចុះបញ្ជីអប្បបរមាក្នុងករណីចាំបាច់ ។

**ប្រការ ១៤.-**

មូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ មិនត្រូវធ្លាក់ចុះទាបជាងកម្រិតដើមទុនចុះបញ្ជីអប្បបរមា ។ ការគណនាមូលនិធិផ្ទាល់សុទ្ធនឹងត្រូវកំណត់ដោយបទប្បញ្ញត្តិធនាគារជាតិនៃកម្ពុជាដោយឡែក ។

**ប្រការ ១៥.-**

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ដែលបានទទួលអាជ្ញាប័ណ្ណ ត្រូវរក្សាប្រាក់តំកល់ធានាដើមទុនស្មើនឹងប្រាំភាគរយ (៥%) នៃដើមទុនដែលបានចុះបញ្ជីនៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា ។ ការកំណត់ការប្រាក់នឹងមានចែងក្នុងបទប្បញ្ញត្តិធនាគារជាតិនៃកម្ពុជាដោយឡែក ។

**ប្រការ ១៦.-**

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវរក្សាមូលនិធិដែលទទួលបានពីអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់សម្រាប់ការផ្ទេរ និង ការចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិកទៅតាមនីតិវិធីដូចខាងក្រោម ៖

១- ត្រូវដាក់តម្កល់ក្នុងគណនីដោយឡែកនៅក្នុងគ្រឹះស្ថានធនាគារពាណិជ្ជ ដែលមានរូបភាពជាគណនីអាណត្តិព្យាបាល ឬវិនិយោគលើទ្រព្យសកម្មមានសុវត្ថិភាព មានហានិភ័យទាប និងមានសន្ទនីយភាពខ្ពស់ ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា

២- មូលនិធិនេះមិនមែនជាទ្រព្យសម្បត្តិរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់នោះទេ ។ អត្ថប្រយោជន៍ដែលទទួលបានពីការតម្កល់មូលនិធិត្រូវរក្សាទុក និងប្រើប្រាស់ជាប្រយោជន៍សម្រាប់អ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់

៣- ក្នុងករណីគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់បញ្ឈប់សកម្មភាពអាជីវកម្ម ឬក្ស័យធន មូលនិធិត្រូវឃាត់ទុកដើម្បីទូទាត់សងទៅអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់វិញ

៤- គ្រឹះស្ថានធនាគារដែលរក្សាមូលនិធិ ត្រូវមានតួនាទីត្រួតពិនិត្យ និងផ្ទៀងផ្ទាត់សមតុល្យគណនីអាណត្តិព្យាបាលជាមួយសមតុល្យមូលនិធិដែលបានទទួលពីការផ្ទេរប្រាក់ និង

ការចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិក ។

**ប្រការ ១៧.-**

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ដែលមានបំណងប្រើប្រាស់ភ្នាក់ងារ ដែលធ្វើសកម្មភាពជំនួសខ្លួន ត្រូវបំពេញកាតព្វកិច្ចដូចខាងក្រោម ៖

១- រាយការណ៍មកធនាគារជាតិនៃកម្ពុជាអំពីព័ត៌មានពាក់ព័ន្ធភ្នាក់ងារ ដូចជា នាមករណ៍ និងអាសយដ្ឋាន ប្រភេទប្រតិបត្តិការ និងទំហំសកម្មភាពប្រតិបត្តិការ

២- ត្រូវមានលក្ខខណ្ឌសមស្របក្នុងការជ្រើសរើសភ្នាក់ងារ និងខចែងអំពីមុខងារ និងការទទួលខុសត្រូវស្របតាមច្បាប់ជាធរមាន

៣- ធានាថាគ្រប់ភ្នាក់ងារប្រតិបត្តិដោយមានការត្រួតពិនិត្យពេញលេញ និងគោរពតាមគោលការណ៍និងនីតិវិធីទាំងឡាយដែលបានដាក់ចេញ ។

**ប្រការ ១៨.-**

ក្នុងករណីដែលគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ មានបំណងផ្តល់មុខងារប្រតិបត្តិការទូទាត់សងប្រាក់ទៅឱ្យអ្នកផ្តល់សេវាជំនួស គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ត្រូវសុំការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ។

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវធានាថាអ្នកផ្តល់សេវាជំនួសស្ថិតនៅក្រោមវិសាលភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួន និងការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ។

**ប្រការ ១៩.-**

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវទទួលខុសត្រូវទាំងស្រុងនូវរាល់សកម្មភាពប្រតិបត្តិការរបស់ខ្លួន ឬក៏រួមទាំងសកម្មភាពប្រតិបត្តិការរបស់ និយោជិត ភ្នាក់ងារ ឬអ្នកផ្តល់សេវាជំនួសដែលខ្លួនបានជ្រើសរើស ។

**ប្រការ ២០.-**

១- នីតិបុគ្គលទាំងឡាយណាក្រៅពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវបានហាមឃាត់ក្នុងការចេញផ្សាយរូបិយវត្ថុជាអេឡិចត្រូនិក ។ ការចេញផ្សាយរូបិយវត្ថុជាអេឡិចត្រូនិកត្រូវអនុលោមទៅតាមលក្ខខណ្ឌដូចខាងក្រោម ៖

ក) មូលនិធិទទួលបានពីការចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិក មិនត្រូវចាត់ទុកថាជាប្រាក់បញ្ញើនោះទេ

ខ) ត្រូវចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិកតាមតម្លៃចារឹកស្មើនឹងមូលនិធិដែលទទួលបាន

គ) ត្រូវបំបែងមូលនិធិដែលទទួលបានពីអតិថិជនទៅជារូបិយវត្ថុអេឡិចត្រូនិកដោយមិនមានការពន្យារពេល និងអាចប្រើប្រាស់បានភ្លាមៗ

ឃ) ត្រូវផ្ទេរមូលនិធិ ដែលទទួលបានពីអតិថិជនទៅក្នុងគណនីអាណត្តិព្យាបាល ដែលបានបើកនៅគ្រឹះស្ថានធនាគារពាណិជ្ជ ហើយរក្សាទុកនៅក្នុងគណនីនោះក្នុងអំឡុងពេលប្រើប្រាស់

ង) មិនត្រូវផ្តល់ការប្រាក់ ឬ ផលប្រយោជន៍ផ្សេងទៀតទៅកាន់អ្នកប្រើប្រាស់ក្នុងអំឡុងពេលនៃការកាន់កាប់រូបិយវត្ថុអេឡិចត្រូនិក

ច) ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីលក្ខខណ្ឌក្នុងការផ្ទេររូបិយវត្ថុអេឡិចត្រូនិកជាសាច់ប្រាក់

ឆ) លក្ខខណ្ឌផ្សេងទៀតដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ។

២- ការចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិកក្នុងករណីដូចខាងក្រោម មិនតម្រូវឱ្យមានការស្នើសុំអាជ្ញាប័ណ្ណ ប៉ុន្តែត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន មកធនាគារជាតិនៃកម្ពុជា ៖

ក) កម្រិតអតិបរមានៃសមតុល្យគណនីនីមួយៗមិនលើសពី ២០០.០០០ រៀល (ពីររយពាន់រៀល) ឬសមមូល

ខ) សមតុល្យគណនីសរុបមិនលើសពី ៨០០.០០០.០០០ រៀល (ប្រាំបីរយលានរៀល) ឬ សមមូល

គ) រូបិយវត្ថុអេឡិចត្រូនិកប្រើប្រាស់សម្រាប់ទូទាត់លើផលិតផល ឬ សេវាកម្មដែលផ្តល់ដោយរូបវន្តបុគ្គលតែមួយ

ឃ) លក្ខខណ្ឌផ្សេងទៀតដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ។

**ប្រការ ២១.-**

ដើម្បីធានានូវសុវត្ថិភាព និងប្រសិទ្ធភាពក្នុងការផ្តល់សេវាទូទាត់ដល់សាធារណជន គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ត្រូវអនុវត្តដូចខាងក្រោម ៖

១- រៀបចំប្រព័ន្ធប្រតិបត្តិការសុវត្ថិភាពឱ្យមានភាពរឹងមាំ ដើម្បីរក្សានូវជំនឿទុកចិត្តរបស់អតិថិជនក្នុងការប្រើប្រាស់សេវារបស់ខ្លួន

២- មានធនធានមនុស្សនិងសមត្ថភាព រួមទាំងផ្នែកឧបករណ៍បច្ចេកទេសគ្រប់គ្រាន់សម្រាប់ដំណើរការប្រព័ន្ធឱ្យមានសុវត្ថិភាព និងប្រសិទ្ធភាព

៣- រៀបចំចងក្រងនីតិវិធីប្រតិបត្តិការ និងបច្ចេកទេសឱ្យបានច្បាស់លាស់

៤- រៀបចំយន្តការត្រួតពិនិត្យប្រព័ន្ធផ្ទៃក្នុងឱ្យមានភាពរឹងមាំ

៥- ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធ និងដំណើរការសាកល្បងប្រព័ន្ធជាប្រចាំ

៦- រៀបចំផែនការសង្គ្រោះបន្ទាន់ រួមទាំងបង្កើតនូវប្រព័ន្ធសម្រាប់សង្គ្រោះទិន្នន័យ

៧- រៀបចំប្រព័ន្ធសម្រាប់តាមដានប្រតិបត្តិការបន្លំឆបោក ព្រមទាំងយុទ្ធសាស្ត្រក្នុងការកំណត់អត្តសញ្ញាណហានិភ័យ ។

**ប្រការ ២២.-**

ដើម្បីការពារអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ត្រូវ ៖

១- ផ្តល់នូវព័ត៌មានចាំបាច់មួយចំនួន ដល់អតិថិជនមុននឹងអតិថិជនសម្រេចប្រើសេវាទូទាត់សងប្រាក់របស់ខ្លួនដូចជា ៖

ក) កម្រៃសេវាអ្នកផ្ញើ និងអ្នកទទួល

ខ) ប្រភេទសេវាដែលផ្តល់

គ) អត្រាប្តូរប្រាក់

ឃ) ថ្លៃផ្សេងៗទៀត

ង) មធ្យោបាយនិងទីតាំងដែលអតិថិជនអាចប្រើប្រាស់សេវា

ច) ពេលវេលាដែលអ្នកទទួលអាចដកប្រាក់បាន

ឆ) ពេលវេលាក្នុងការដោះស្រាយវិវាទ ។

២- រៀបចំលក្ខខណ្ឌ និងខចែងអំពីការប្រើប្រាស់សេវា រួមទាំងការទទួលខុសត្រូវរបស់គ្រប់ភាគីពាក់ព័ន្ធ

៣- ផ្តល់ព័ត៌មាន និងលក្ខខណ្ឌពាក់ព័ន្ធទៅនឹងសេវារបស់ខ្លួន ដូចបានរៀបរាប់ខាងលើទៅអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់មានលក្ខណៈងាយយល់ ច្បាស់លាស់ និងភាពងាយស្រួលក្នុងការទទួលបាន ។

៤- ជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអតិថិជនរបស់ខ្លួនយ៉ាងយូរបំផុត ២១ថ្ងៃ មុននឹងមានការកែប្រែចំណុចសំខាន់ៗរបស់លក្ខខណ្ឌ និងខចែងនៃគណនីរបស់អតិថិជនដែលតម្រូវឲ្យផ្សព្វផ្សាយ លើកលែងតែការកែប្រែទាំងនោះចាំបាច់ត្រូវតែធ្វើភ្លាមៗដើម្បីរក្សានិងរៀបចំឡើងវិញនូវសុវត្ថិភាពប្រព័ន្ធ ឬគណនីរបស់អតិថិជន ។

៥- ផ្តល់វិក្កយបត្រ ឬភស្តុតាងសម្គាល់ជូនអ្នកផ្ញើ និងអ្នកទទួល នៅពេលធ្វើប្រតិបត្តិការបានជោគជ័យ

៦- រក្សាទុកវិក្កយបត្រ ឬឯកសារផ្សេងៗ ដែលអតិថិជនធ្វើប្រតិបត្តិការសម្រាប់ធ្វើការត្រួតពិនិត្យ

៧- រៀបចំនីតិវិធីក្នុងការដោះស្រាយវិវាទជាមុនជូនអតិថិជន និងផ្តល់ក្នុងករណីមានវិបត្តិ ឬ មានការតវ៉ាកើតឡើងក្នុងការទូទាត់ ដើម្បីឱ្យអតិថិជនអាចទំនាក់ទំនងរកជំនួយបានភ្លាមៗ ។

**ប្រការ ២៣.-**

ដើម្បីរួមចំណែកអនុវត្តច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ត្រូវបំពេញកាតព្វកិច្ចជាអាទិ៍ដូចខាងក្រោម ៖

១- រៀបចំបង្កើតនូវប្រព័ន្ធផ្ទៃក្នុងសម្រាប់ត្រួតពិនិត្យ និងតាមដានប្រតិបត្តិការសាច់ប្រាក់ និងប្រតិបត្តិការសង្ស័យ

២- កំណត់ឱ្យបានច្បាស់លាស់អំពីនីតិវិធីក្នុងការស្គាល់អត្តសញ្ញាណអតិថិជន និងវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន

៣- រាយការណ៍អំពីប្រតិបត្តិការសង្ស័យ និងប្រតិបត្តិការសាច់ប្រាក់ទៅកាន់អាជ្ញាធរពាក់ព័ន្ធ

៤- តែងតាំងមន្ត្រីប្រតិបត្តិទទួលបន្ទុកការងារពាក់ព័ន្ធការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

៥- ជានាថាតតិយភាគីណាមួយដែលធ្វើសកម្មភាពជំនួសខ្លួនគោរពតាមច្បាប់ ដូចមានចែងនៅក្នុងប្រការនេះ ។

**ប្រការ ២៤.-**

១- គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដែលមានបំណងធ្វើសកម្មភាពណាមួយដូចខាងក្រោម ត្រូវស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា ៖

ក) ការរួមបញ្ចូលជាមួយគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ឬអង្គភាពផ្សេងទៀត

ខ) ការរំសាយ ឬការបញ្ឈប់អាជីវកម្ម

គ) ផ្ទេរនិងធ្វើលទ្ធកម្មនូវអាជីវកម្មមួយផ្នែកឬទាំងមូល ។

២- អាជ្ញាប័ណ្ណរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់នឹងត្រូវបញ្ឈប់ដោយស្វ័យប្រវត្តិតាមលក្ខខណ្ឌដូចខាងក្រោម ៖

ក) នៅកាលបរិច្ឆេទដែលរូបភាពគតិយុត្តត្រូវបានបញ្ឈប់ដោយច្បាប់

ខ) នៅកាលបរិច្ឆេទបញ្ឈប់សកម្មភាពអាជីវកម្ម

គ) អាជ្ញាប័ណ្ណអស់សុពលភាព ។

**ប្រការ ២៥.-**

រាល់ការផ្លាស់ប្តូររចនាសម្ព័ន្ធភាគទុនិក គណៈគ្រប់គ្រង នីតិវិធីប្រតិបត្តិការ និងការផ្លាស់ប្តូរសំខាន់ៗផ្សេងទៀតត្រូវស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា ។

**ប្រការ ២៦.-**

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវគោរពតាមការសម្ងាត់វិជ្ជាជីវៈ ដូចមានចែងក្នុងមាត្រា ៩៧ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

## ជំពូកទី ៤
## ការត្រួតពិនិត្យ

**ប្រការ ២៧.-**

ធនាគារជាតិនៃកម្ពុជា នឹងចុះត្រួតពិនិត្យប្រចាំឆ្នាំចំពោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់និងភ្នាក់ងារ បន្ទាប់ពីបានជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន ចំនួន ១៥ ថ្ងៃ (ដប់ប្រាំថ្ងៃ) ធ្វើការ ។ ធនាគារជាតិនៃកម្ពុជា អាចចុះត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់និងភ្នាក់ងារនៅពេលណាមួយក៏បាន ដោយពុំមានការជូនដំណឹងជាមុនឡើយ ប្រសិនបើធនាគារជាតិនៃកម្ពុជាមានហេតុផលជឿថា គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងភ្នាក់ងារ កំពុងធ្វើសកម្មភាពមិនត្រឹមត្រូវ គ្មានសុវត្ថិភាព ឬបានបំពាន ឬកំពុងបំពានប្រកាសនេះ ឬបទបញ្ជាដែលចេញផ្សាយក្រោមប្រកាសនេះ ។

**ប្រការ ២៨.-**

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវផ្តល់ព័ត៌មានតាមការស្នើសុំរបស់ធនាគារជាតិនៃកម្ពុជា និងត្រូវរៀបចំសៀវភៅកត់ត្រា កំណត់ហេតុ គណនី ឧបករណ៍ ឬឯកសារពាក់ព័ន្ធអាជីវកម្មរបស់ខ្លួន ឬអាជីវកម្មពាក់ព័ន្ធ សម្រាប់គោលបំណងត្រួតពិនិត្យរបស់អ្នកត្រួតពិនិត្យដែលតែងតាំងដោយធនាគារជាតិនៃកម្ពុជា ទៅតាមពេលវេលា និងការរៀបចំដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ។

**ប្រការ ២៩.-**

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវផ្តល់របាយការណ៍ជូនធនាគារជាតិនៃកម្ពុជា យ៉ាងយូរបំផុតត្រឹមថ្ងៃទី១០នៃខែបន្ទាប់ តាមគំរូតារាងរបាយការណ៍ដែលបានរៀបចំ និងទៅតាមកាលបរិច្ឆេទជាក់លាក់ចំពោះព័ត៌មានផ្សេងៗទៀតដែលជាការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៣០.-**

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវរក្សាទុកនូវរាល់កំណត់ត្រាសកម្មភាពនានារបស់ខ្លួនអំពីព័ត៌មានប្រតិបត្តិការនីមួយៗយ៉ាងហោចណាស់រយៈពេល ០៥ ឆ្នាំ (ប្រាំឆ្នាំ) ។

កំណត់ត្រាទាំងអស់ដែលបានរក្សាទុក ត្រូវបើកចំហសម្រាប់ធ្វើការត្រួតពិនិត្យដោយធនាគារជាតិនៃកម្ពុជា ។

## ជំពូកទី ៥
## ទោសប្បញ្ញត្តិ

**ប្រការ ៣១.-**

បុគ្គលណាដែលរំលោភលើបញ្ញត្តិដូចមានចែងក្នុងប្រកាសនេះ នឹងត្រូវទទួលរងការដាក់ទណ្ឌកម្មវិន័យ ឬ ពិន័យ ដូចមានចែងក្នុងមាត្រា ៥២ និង ៥៤ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ៣២.-**

ធនាគារជាតិនៃកម្ពុជា អាចព្យួរឬដកហូតអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់នៅក្នុងលក្ខខណ្ឌដូចខាងក្រោម ៖

១- ខកខានធ្វើប្រតិបត្តិការក្នុងរយៈពេល ៦ ខែ (ប្រាំមួយខែ) គិតចាប់ពីកាលបរិច្ឆេទទទួលបានអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការ ឬផ្អាកសកម្មភាពប្រតិបត្តិការរយៈពេល ៦ ខែ (ប្រាំមួយខែ)

២- ជូនដំណឹងមកធនាគារជាតិនៃកម្ពុជាបញ្ជាក់អំពីការលះបង់សិទ្ធិធ្វើប្រតិបត្តិការ ឬ ផ្អាកប្រតិបត្តិការរបស់ខ្លួន

៣- បានប្រព្រឹត្តការក្លែងបន្លំព័ត៌មាន និងឯកសារដោយចេតនា ឬ មានការធ្វេសប្រហែសធ្ងន់ធ្ងរ

៤- មិនអាចបំពេញបានតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៩ នៃប្រកាសនេះ

៥- មិនគោរពតាមសេចក្តីណែនាំ ឬសេចក្តីជូនដំណឹងរបស់ធនាគារជាតិនៃកម្ពុជា

៦- ធ្វើប្រតិបត្តិការដែលពុំមានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា

៧- បង្កឱ្យមានការគំរាមកំហែងដល់សុវត្ថិភាព ប្រសិទ្ធភាព និងភាពរឹងមាំ របស់ប្រព័ន្ធទូទាត់សងប្រាក់ជាតិទាំងមូល ។

**ប្រការ ៣៣.-**

ក្នុងករណីមានការយឺតយ៉ាវចំពោះ ៖

១) ក្នុងការផ្តល់របាយការណ៍និងព័ត៌មានផ្សេងៗ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់នឹងត្រូវទទួលរងការផាកពិន័យចំនួន ១.០០០.០០០ រៀល (មួយលានរៀល) ក្នុងមួយថ្ងៃ ។ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់នឹងត្រូវទទួលរងការផាកពិន័យធ្ងន់ធ្ងរឡើងប្រសិនបើនៅតែបន្តការយឺតយ៉ាវ ។

២) ការបង់សោហ៊ុយអាជ្ញាប័ណ្ណមានការយឺតយ៉ាវ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ត្រូវទទួលរងនូវការផាកពិន័យ ដោយត្រូវបង់ការប្រាក់លើចំនួនប្រាក់ដែលនៅមិនទាន់បានបង់តាមអត្រាការប្រាក់បុនហិរញ្ញប្បទានជាធរមាន ក្នុងរយៈពេលរហូតដល់ ៣០ ថ្ងៃ (សាមសិបថ្ងៃ) ។

## ជំពូកទី ៦
## អន្តរប្បញ្ញត្តិ

**ប្រការ ៣៤.-**

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដែលនៅមានសុពលភាពអាជ្ញាប័ណ្ណស្ថិតនៅក្រោមប្រកាសស្តីពី "អ្នកដំណើរការតតិយភាគី" ត្រូវបំពេញបែបបទស្នើសុំអាជ្ញាប័ណ្ណឡើងវិញក្នុងរយៈពេលយ៉ាងយូរបំផុត ៦ ខែ (ប្រាំមួយខែ) ដោយអនុលោមតាមខ្លឹមសារប្រកាសនេះ លើកលែងចំពោះគ្រឹះស្ថានដែលមានប្រតិបត្តិការដូចចែងក្នុងប្រការ ៤ (ចំណុច ១) ។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**ប្រការ ៣៥.-**

អគ្គលេខាធិការ អគ្គនាយកបច្ចេកទេស អគ្គបេឡា អគ្គនាយកត្រួតពិនិត្យ អគ្គពិនិត្យ ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៣៦.-**

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែមិថុនាឆ្នាំ ២០១៧

**ទេសាភិបាល**

ជា.ចាន់តូ

**កន្លែងទទួល៖**
- ដូចប្រការ ៣៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ចម្លងជូន៖**
- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

# សុន្ទរកថា
# ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ និង ទិសដៅការងារឆមាសទី២ ឆ្នាំ២០១៧ របស់ធនាគារជាតិនៃកម្ពុជា

**មជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៧**

**សូមគោរព៖**

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយជាអនេក ដែលបានចូលរួមក្នុងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៧ របស់ធនាគារជាតិនៃកម្ពុជា។ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ដែលមានវត្តមាននៅក្នុងសន្និបាតនាពេលនេះ ដែលមានចំនួនប្រមាណ ១.២០០ នាក់ ស្មើនឹងជិត ៨០% នៃចំនួនមន្ត្រីបុគ្គលិកសរុបមកពីស្នាក់ការកណ្តាល និងបណ្តាសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត។ ការអញ្ជើញឱ្យមន្ត្រីបុគ្គលិកយើងបានចូលរួមច្រើនកុះករបែបនេះ គឺដើម្បីអបអរសាទរនិងផ្សព្វផ្សាយលទ្ធផលការងារដែលសម្រេចបាន និងទិសដៅការងារនាពេលខាងមុខឱ្យបានកាន់តែទូលំទូលាយ ជាពិសេស រហូតទៅដល់មន្ត្រីវ័យក្មេងរបស់យើង។ ម៉្យាងទៀត ការជួបជុំគ្នានាឱកាសនេះ ក៏នឹងបង្កលក្ខណៈឱ្យមន្ត្រីយើងបង្កើនស្មារតីសហការគ្នា សាមគ្គីភាពនិងភាតរភាព ក្នុងនាមជាសមាជិកគ្រួសារធនាគារជាតិនៃកម្ពុជាតែមួយ។ លើសពីនេះ សន្និបាតរបស់យើងក៏ត្រូវបានធ្វើឡើង បន្ទាប់ពីប្រជាពលរដ្ឋទូទាំងប្រទេសមានសេចក្តីរីករាយឥតឧបមា និងបានចូលរួមអបអរសាទរការដាក់បញ្ចូលតំបន់ប្រាសាទសំបូរព្រៃគុក ក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌ពិភពលោកកាលពីថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៧ ដោយកិច្ចប្រជុំគណៈកម្មាធិការបេតិកភណ្ឌពិភពលោកនៃអង្គការ UNESCO។ ការដាក់បញ្ចូលនេះគឺជាមោទនភាពជាតិថ្មីមួយទៀត ដែលរាជរដ្ឋាភិបាលសម្រេចបានក្នុងការបង្ហាញពិភពលោកពីស្នាដៃដ៏វិសិដ្ឋរបស់បុព្វបុរសខ្មែរ ដែលបានកសាងប្រាសាទដ៏ល្អវិចិត្រនានាជាច្រើនលើទឹកដីសុវណ្ណភូមិរបស់យើង។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំសូមជម្រាបជូនអង្គសន្និបាតពីស្ថានភាពនិងទស្សនវិស័យកំណើនសេដ្ឋកិច្ចកម្ពុជាលទ្ធផលចម្បងៗដែលធនាគារជាតិនៃកម្ពុជាសម្រេចបាននៅក្នុងឆមាសទី១ ឆ្នាំ២០១៧នេះ និងទិសដៅការងារសំខាន់ៗនាពេលខាងមុខ ដូចតទៅ៖

## I/- ស្ថានភាពនិងទស្សនវិស័យកំណើនសេដ្ឋកិច្ចកម្ពុជា

នៅក្នុងឆមាសទី១ ឆ្នាំ២០១៧ នេះ សេដ្ឋកិច្ចកម្ពុជាទទួលបានអំណោយផលពីភាពប្រសើរឡើងនៃសេដ្ឋកិច្ចពិភពលោក។ ភាពប្រសើរឡើងនេះ ជាចម្បងដោយសារការបន្តកើនឡើងនៃកំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសអភិវឌ្ឍន៍ ជាពិសេស សហរដ្ឋអាមេរិក តំបន់អឺរ៉ូ និងជប៉ុន ខណៈប្រទេសចិនល្បឿនកំណើនបានបន្តថយចុះបន្តិចបន្តួចដូចការរំពឹងទុក។ នៅតំបន់អាស៊ានសកម្មភាព សេដ្ឋកិច្ចបន្តរក្សាល្បឿនកំណើនខ្ពស់ជាមួយនឹងនិន្នាការកើនឡើងបន្តិចបន្តួចថែមទៀត ដែលគាំទ្រដោយតម្រូវការខាងក្នុងនិងអំណោយផលពីកត្តាខាងក្រៅ។

ស្ថិតក្នុងបរិការណ៍នេះ សកម្មភាពសេដ្ឋកិច្ចចម្បងៗរបស់កម្ពុជាបានបន្តកើនឡើងយ៉ាងរឹងមាំនៅឆមាសទី១ ឆ្នាំ២០១៧។ វិស័យកាត់ដេរនៅតែបន្តរួមចំណែកចម្បងក្នុងកំណើន ថ្វីត្បិតតែអត្រាកំណើនបានថមថយបន្តិចក៏ដោយ ក្នុងពេលដែលវិស័យសំណង់បន្តមានកំណើនរឹងមាំ ហើយវិស័យទេសចរណ៍មានសន្ទុះកំណើនគួរឱ្យកត់សម្គាល់។ ចំណែកឯវិស័យកសិកម្ម កំណើនបានបន្តងើបឡើងទន់ខ្សោយនៅឡើយ។ ទន្ទឹមនេះ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងស្ថិរភាពហិរញ្ញវត្ថុត្រូវបានរក្សាយ៉ាងរឹងមាំ ដែលជាមូលដ្ឋានគាំទ្រដល់ការរីកចម្រើនប្រកបដោយចីរភាពរបស់សកម្មភាពសេដ្ឋកិច្ចនាពេលខាងមុខ។ ផ្អែកលើស្ថានភាពល្អប្រសើរនេះ សកម្មភាពសេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថា នឹងបន្តបោះជំហានទៅមុខយ៉ាងស្វាហាប់នៅឆមាសទី២ ដែលអាចធ្វើឱ្យកំណើនសេដ្ឋកិច្ចកម្ពុជាទទួលបានក្នុងអត្រា ៧% នៅឆ្នាំ២០១៧។

ទោះយ៉ាងណា សេដ្ឋកិច្ចកម្ពុជាក៏ប្រឈមនឹងហានិភ័យមួយចំនួន ដែលអាចប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចផងដែរ ទាំងកត្តាខាងក្រៅ និងខាងក្នុង។ កត្តាខាងក្រៅរួមមាន៖ i/-ការឡើងថ្លៃនៃប្រាក់ដុល្លារអាមេរិកនឹងអាចកាត់បន្ថយសមត្ថភាពប្រកួតប្រជែង ចំពោះការនាំចេញកម្ពុជានឹងអាចមានផលប៉ះពាល់ដល់វិស័យទេសចរណ៍ផងដែរ ii/-ភាពមិនច្បាស់លាស់ពីឥទ្ធិពលនៃការចាកចេញរបស់អង់គ្លេសពីសហភាពអឺរ៉ុបលើការនាំចេញរបស់កម្ពុជាទៅអង់គ្លេស និង iii/-ការកើនឡើងភាពប្រកួតប្រជែងទំនិញនាំចេញរបស់កម្ពុជាជាមួយប្រទេសក្នុងតំបន់។ កត្តាខាងក្នុងរួមមាន៖ i/-ការកើនឡើងនៃប្រាក់ឈ្នួលកម្មករ ដែលអាចបង្កើនសម្ពាធលើថ្លៃដើមផលិតកម្ម និង ii/-ការថយចុះថ្លៃផលិតផលកសិកម្ម និងកសិឧស្សាហកម្មក្នុងស្រុក។

## II- លទ្ធផលនិងទិសដៅការងារចម្បងៗរបស់ធនាគារជាតិនៃកម្ពុជា

ក្នុងនាមជាអាជ្ញាធររូបិយវត្ថុ អាជ្ញាធរត្រួតពិនិត្យវិស័យធនាគារនិងគ្រប់គ្រងប្រព័ន្ធទូទាត់សងប្រាក់ធនាគារជាតិនៃកម្ពុជាបានបន្តចូលរួមយ៉ាងសកម្មក្នុងការគាំទ្រ និងជំរុញកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ ជាពិសេស តាមរយៈការរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ស្ថិរភាពហិរញ្ញវត្ថុ ការអភិវឌ្ឍវិស័យធនាគារ និងការធ្វើទំនើបកម្មប្រព័ន្ធទូទាត់។

**១/- ការរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច៖** នៅក្នុងឆមាសទី១នេះ អត្រាអតិផរណាបន្តមានកម្រិតទាបអាចគ្រប់គ្រងបានជាមធ្យម ៣,៦% បើធៀបនឹងគ្រាដូចគ្នាឆ្នាំមុនខ្ពស់ជាងបន្តិច ដោយសារការកើនឡើងតម្លៃប្រេង និងកំណើនថេរនៃថ្លៃម្ហូបអាហារ។ ការបន្តរក្សាបានស្ថិរភាពអត្រាប្តូរប្រាក់រៀល ធៀបនឹងប្រាក់ដុល្លារអាមេរិក ដែលស្ថិតក្នុងកម្រិតមធ្យម ៤.០២៣ រៀល/ដុល្លារអាមេរិកនិងការគ្រប់គ្រងបរិមាណផ្គត់ផ្គង់រូបិយវត្ថុឱ្យស្ថិតក្នុងកម្រិតសមស្របបានរួមចំណែកយ៉ាងសំខាន់ក្នុងការរក្សាស្ថិរភាពថ្លៃនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ អតិផរណារំពឹងថានឹងបន្តស្ថិតក្នុងកម្រិតទាបប្រមាណ ៣,៥% នៅឆមាសទី២ និងជាមធ្យម ៣,៥% សម្រាប់ឆ្នាំ២០១៧ ដោយសារអតិផរណា ការនាំចូលរំពឹងថាមានកម្រិតទាប ក្នុងពេលដែលថ្លៃប្រេងឥន្ធនៈមានស្ថិរភាព និងកំណើនឥណទានបន្តថមថយជាមួយនឹងការបន្តអនុវត្តគោលនយោបាយរក្សាស្ថិរភាព

ប្រាក់រៀល។ ទន្ទឹមនេះ ដោយសារកំណើនតម្រូវការប្រាក់រៀលនិងការគ្រប់គ្រងដោយប្រសិទ្ធភាពលើទុនបម្រុងអន្តរជាតិ ធនាគារជាតិនៃកម្ពុជាគរពូនទុនបម្រុងអន្តរជាតិដល់ប្រមាណ ៧,៧ ប៊ីលានដុល្លារអាមេរិក ដែលអាចធានាការនាំចូលទំនិញ និងសេវាបានរហូតដល់ ៦ខែ គឺខ្ពស់ជាងពីរដងនៃកម្រិតដែលប្រទេសកំពុងអភិវឌ្ឍន៍គួរមាន។

ប្រឈមនឹងស្ថានភាពដុល្លារូបនីយកម្មខ្ពស់ រាជរដ្ឋាភិបាលក៏ដូចជាធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវវិធានការជាបន្តបន្ទាប់លើការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ដែលមានលក្ខណៈទន់ភ្លន់ និងផ្អែកលើយន្តការទីផ្សារ ក្រោមការសិក្សាដោយគ្រប់ជ្រុងជ្រោយលើផលប៉ះពាល់មកលើសេដ្ឋកិច្ច។ លើបន្ទាត់គោលនយោបាយនេះ ឧបករណ៍គោលនយោបាយរូបិយវត្ថុកំពុងត្រូវបានអភិវឌ្ឍ ដូចជា មូលបត្រអាចជួញដូរបាន (NCD) ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ហើយផ្លែតហ្វមរបស់ធនាគារជាតិនៃកម្ពុជា (NBCP) កំពុងត្រៀមដាក់ឱ្យដំណើរការ ដើម្បីសម្រួលការជួញដូរ NCD ការទិញលក់រូបិយវត្ថុ និងរូបិយប័ណ្ណ និងប្រតិបត្តិការ LPCO។

**២/- ការអភិវឌ្ឍវិស័យធនាគារនិងការរក្សាស្ថិរភាពហិរញ្ញវត្ថុ ៖** វិស័យធនាគារកម្ពុជាបានបន្តរីកចម្រើនប្រកបដោយភាពរឹងមាំមានលក្ខណៈប្រកួតប្រជែង និងបរិយាប័ន្ន។ គិតត្រឹមឆមាសទី១ នេះ ទ្រព្យសកម្មវិស័យធនាគារមានកំណើនដល់ ១៥០% នៃផ.ស.ស ប្រាក់បញ្ញើមានកំណើនដល់ ៨៥% នៃផ.ស.ស ហើយឥណទានទៅកាន់វិស័យឯកជនបានកើនឡើងដល់ ៩២% នៃផ.ស.ស។ យោងតាមការវាយតម្លៃរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ការអភិវឌ្ឍវិស័យធនាគាររបស់កម្ពុជាក្នុងដំណាក់កាលបច្ចុប្បន្ននៅតែបន្តជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ ទន្ទឹមនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យធនាគារ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញវិធានការម៉ាក្រូ និងមីក្រូប្រុងប្រយ័ត្នតាមដំណាក់កាលនិងជាបន្តបន្ទាប់ ស្របតាមស្ថានភាពជាក់ស្តែង ព្រមទាំងពង្រឹងការត្រួតពិនិត្យវិស័យធនាគារ ជាពិសេស ផ្អែកលើហានិភ័យនិងទស្សនៈអនាគតសំដៅរក្សាស្ថិរភាពហិរញ្ញវត្ថុ។ ម្យ៉ាងទៀត ប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវបានពង្រឹងនិងធ្វើឱ្យប្រសើរឡើង ដើម្បីរួមចំណែកក្នុងការកាត់បន្ថយហានិភ័យឥណទាននិងបង្កើនតម្លាភាព។ លើសពីនេះ គម្រោងការពារអ្នកដាក់ប្រាក់បញ្ញើក៏កំពុងត្រូវបានអភិវឌ្ឍ សម្រាប់ពង្រឹងជំនឿទុកចិត្តរបស់អ្នកដាក់ប្រាក់បញ្ញើក្នុងវិស័យធនាគារបន្ថែមទៀត។

ដើម្បីជួយសម្រាលបន្ទុករបស់ប្រជាពលរដ្ឋឱ្យទទួលបានឥណទានក្នុងតម្លៃសមរម្យ សម្រាប់បង្កបង្កើនផលនិងពង្រីកអាជីវកម្មផ្សេងៗទប់ស្កាត់បំណុលវ័ណ្ឌកនិងជៀសវាងព្រឹទ្ធិកម្មរបស់គ្រឹះស្ថានហិរញ្ញវត្ថុមួយចំនួនតូច ធនាគារជាតិនៃកម្ពុជាបានសម្រេចដាក់ពិដានអត្រាការប្រាក់ ១៨% ចំពោះឥណទាន ដែលផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិងប្រតិបត្តិករឥណទានជនបទនៅកម្ពុជា ក្រោយពីបានសិក្សាយ៉ាងល្អិតល្អន់និងគ្រប់ជ្រុងជ្រោយពីផលប៉ះពាល់។ ការដាក់ពិដាននេះ ក៏មានចេតនាជំរុញឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិងប្រតិបត្តិករឥណទានទាំងនោះ បង្កើនប្រសិទ្ធភាពប្រតិបត្តិការអាជីវកម្ម តាមរយៈការកាត់បន្ថយចំណាយឬការច្របាច់បញ្ចូលគ្នាផងដែរ។ ទន្ទឹមនេះ ការលើកកម្ពស់អក្ខរកម្មហិរញ្ញវត្ថុនៅតែជាគោលនយោបាយអាទិភាពរបស់ធនាគារជាតិនៃកម្ពុជា ដែលត្រូវបានបន្តពង្រឹង តាមរយៈការធ្វើយុទ្ធនាការ "គោះ! និយាយពីលុយ"។ ម្យ៉ាងទៀត ធនាគារជាតិនៃកម្ពុជាបានធ្វើយុទ្ធនាការទូទាំងប្រទេសតាមរយៈការផ្សព្វផ្សាយតាមទូរស័ព្ទដៃនិងប្រព័ន្ធផ្សព្វផ្សាយនានាការចុះពន្យល់តាមមូលដ្ឋាននិងការប្តូរស្លាកសញ្ញារបស់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុមួយចំនួន ដែលអាចធ្វើឱ្យមានការភាន់ច្រឡំដល់ប្រជាពលរដ្ឋថាគ្រឹះស្ថានហិរញ្ញវត្ថុទាំងនោះ ជារបស់រដ្ឋ។

ស្របពេលដែលប្រទេសនានាលើពិភពលោកបានប្រើប្រាស់បច្ចេកវិទ្យា ដើម្បីបន្ថយចំណាយ និងពង្រីកការប្រើប្រាស់សេវាហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាក៏បានអនុញ្ញាតឱ្យក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុនិងគ្រឹះស្ថានហិរញ្ញវត្ថុផ្តល់សេវាហិរញ្ញវត្ថុផ្អែកលើបច្ចេកវិទ្យាឌីជីថល (Fintech) ផងដែរ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏បានតាមដានយ៉ាងប្រុងប្រយ័ត្នលើការវិវត្តនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីធានាថាបច្ចេកវិទ្យាហិរញ្ញវត្ថុនឹងក្លាយជាមធ្យោបាយមួយទៀត រួមចំណែកដល់ការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុប្រកបដោយចីរភាព។ គិតត្រឹមឆមាសទី១នេះ ប្រជាជនពេញវ័យប្រមាណ ៥៥% នៃប្រជាជនពេញវ័យសរុបកំពុងប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ ដែលមានដូចជា សេវាដាក់ប្រាក់បញ្ញើ ឥណទានទូទាត់ និងភតិសន្យាហិរញ្ញវត្ថុ។

**៣/- ការធ្វើទំនើបកម្មប្រព័ន្ធទូទាត់និងការលើកកម្ពស់សុវត្ថិភាពបច្ចេកវិទ្យា ៖** ដើម្បីគាំទ្រដល់ការរីកចម្រើនសកម្មភាពសេដ្ឋកិច្ច ប្រព័ន្ធទូទាត់ក៏ត្រូវបានធ្វើទំនើបកម្មជាបន្តបន្ទាប់ សំដៅធ្វើឱ្យប្រតិបត្តិការទូទាត់ប្រព្រឹត្តិទៅដោយសុវត្ថិភាព ឆាប់រហ័សនិងចំណាយទាប។ ក្នុងស្មារតីនេះ បន្ទាប់ពីប្រព័ន្ធសម្រាប់សេវាទូទាត់រហ័ស (FAST) ត្រូវបានដាក់ឱ្យដំណើរការប្រកបដោយជោគជ័យ ប្រព័ន្ធ Cambodian Shared Switch (CSS) ដែលតភ្ជាប់ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ (ATM) និងម៉ាស៊ីនឆូតកាត (POS) របស់គ្រឹះស្ថានហិរញ្ញវត្ថុខុសៗគ្នាកំពុងត្រូវបានដាក់ឱ្យប្រើប្រាស់សាកល្បង ហើយរំពឹងថានឹងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅឆមាសទី២ ខាងមុខ។ ម៉្យាងទៀត ប្រព័ន្ធទូទាត់ដុលភ្លាមៗ (RTGS) ក៏កំពុងត្រូវបានអភិវឌ្ឍដើម្បីសម្រួលដល់ការទូទាត់សងប្រាក់តម្លៃធំជាអេឡិចត្រូនិក។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាកំពុងសិក្សាលើការប្រើប្រាស់បច្ចេកវិទ្យា Blockchain ដើម្បីធ្វើឱ្យប្រព័ន្ធទូទាត់កាន់តែរឹងមាំសុវត្ថិភាពខ្ពស់និងកាត់បន្ថយចំណាយប្រតិបត្តិការបន្ថែមទៀត។

ក្នុងស្ថានភាពដែលបច្ចេកវិទ្យាត្រូវបានប្រើប្រាស់ក្នុងប្រព័ន្ធហិរញ្ញវត្ថុកាន់តែច្រើន ធនាគារជាតិនៃកម្ពុជាក៏បានពង្រឹងសុវត្ថិភាពបច្ចេកវិទ្យា ដើម្បីទប់ស្កាត់ហានិភ័យនៃការលួចទិន្នន័យធ្វើឱ្យប្រព័ន្ធមិនដំណើរការ និងឧក្រិដ្ឋកម្មបច្ចេកវិទ្យា (Cybercrime)។ ការពង្រឹងនេះធ្វើឡើងតាមរយៈការអនុវត្តគោលនយោបាយសុវត្ថិភាពបច្ចេកវិទ្យាដោយផ្តោតលើ៖ i/-ការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា ការរក្សាទិន្នន័យនិងការការពារវីរុសព័ត៌មានវិទ្យា និងii/-ការគ្រប់គ្រងលើការប្រើប្រាស់សេវាព័ត៌មានវិទ្យា។ ម៉្យាងទៀត មូលដ្ឋានទិន្នន័យ (Database) នឹងត្រូវបង្កើតឡើងនិងធ្វើស្វ័យប្រវត្តិកម្ម ដើម្បីរក្សាទុកធ្វើមជ្ឈការនិងពង្រឹងភាពត្រឹមត្រូវនៃទិន្នន័យ ដែលនឹងរួមចំណែកលើកកម្ពស់ប្រសិទ្ធភាពការងារបានមួយកម្រិតថែមទៀត។

**៤/-ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ៖** នៅក្នុងស្ថានភាពដែលប្រព័ន្ធធនាគារកំពុងតែអភិវឌ្ឍយ៉ាងឆាប់រហ័សនិងមានភាពប្រទាក់ក្រឡា អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក) បានពង្រឹងការងារប្រកបដោយប្រសិទ្ធភាព តាមរយៈការពង្រឹងការអនុវត្តកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងការពង្រឹងកិច្ចសហប្រតិបត្តិការទាំងក្នុង និងក្រៅប្រទេសជាមួយនឹងបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធ។ ទោះយ៉ាងណា ចំណេះដឹងរបស់បុគ្គលរាយការណ៍នៅទាមទារឱ្យមានការលើកកម្ពស់បន្ថែមទៀត ហើយសមត្ថភាពជំនាញវិភាគ និងត្រួតពិនិត្យក៏ចាំបាច់ត្រូវ បន្តពង្រឹងផងដែរ ដែលទាំងអស់នេះ ជាអាទិភាពចម្បងរបស់ស.ហ.ក។

**៥/-ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ៖** ធនាគារជាតិនៃកម្ពុជាបានបន្តរួមចំណែកយ៉ាងសកម្មក្នុងការពង្រឹងសមាហរណកម្មវិស័យហិរញ្ញវត្ថុ ក្នុងគោលដៅជំរុញសមាហរណកម្មហិរញ្ញវត្ថុ រក្សាស្ថិរភាពហិរញ្ញវត្ថុនិងលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុក្នុងតំបន់ ក្រោមឆ័ត្រសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) តែមួយ។ ទន្ទឹមនេះ យន្តការបង្ការនិងគ្រប់គ្រងវិបត្តិក្រោមពហុភាគីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (CMIM) អាស៊ាន+៣ ដែលជាសំណាញ់សុវត្ថិភាពតំបន់ក៏ត្រូវបានពង្រឹងជាលំដាប់សំដៅរក្សាភាពរឹងមាំនៃវិស័យហិរញ្ញវត្ថុតំបន់។

ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីទទួលបានជំនួយបច្ចេកទេស ផ្លាស់ប្តូរបទពិសោធន៍ និងកិច្ចសហការការងាររួមគ្នានានា។

**៦/-ការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស ៖** បច្ចុប្បន្នយើងបានបង្កើនមូលធនមនុស្សទាំងបរិមាណ និងគុណភាពដោយគិតមកត្រឹមឆមាសទី១នេះ ចំនួនបុគ្គលិកយើងបានកើនដល់ ១.៥៦៩ នាក់ កើនឡើង ១០% ធៀបនឹងគ្រាដូចគ្នាឆ្នាំកន្លងទៅ។ ធនាគារជាតិនៃកម្ពុជាបានបន្តផ្តល់អាទិភាពខ្ពស់ចំពោះគោលនយោបាយអភិវឌ្ឍសមត្ថភាពធនធានមនុស្ស តាមរយៈការបណ្តុះបណ្តាលផ្ទៃក្នុងការបញ្ជូនមន្ត្រីជំនាញទៅសិក្សានៅបរទេសទាំងរយៈពេលខ្លីនិងរយៈពេលវែងនិងការហាត់ការងារ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ដើម្បីជ្រាបពីលទ្ធផលលម្អិតដែលធនាគារជាតិនៃកម្ពុជាសម្រេចបាន និងទិសដៅការងារសំខាន់ៗ សំដៅទទួលបានសមិទ្ធផលថ្មីៗថែមទៀតក៏ដូចជាដោះស្រាយបញ្ហាប្រឈមនានា ខ្ញុំសូមអង្គសន្និបាតមេត្តាត្រងត្រាប់ស្តាប់បទឧទ្ទេសនាមរបស់ថ្នាក់ដឹកនាំយើង ដែលនឹងរាយការណ៍ជូនអង្គសន្និបាតនាពេលបន្តិចទៀតនេះ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណជាភិយ្យោភាព ចំពោះក្រុមប្រឹក្សាភិបាល និងមន្ត្រី-បុគ្គលិកគ្រប់ជាន់ថ្នាក់របស់ធនាគារជាតិនៃកម្ពុជា ដែលបានខិតខំប្រឹងប្រែងក្នុងការបំពេញមុខងារភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីសម្រេចបានសមិទ្ធផលដ៏ប្រសើរជាបន្តបន្ទាប់ នារយៈពេលកន្លងមក។ ខ្ញុំក៏សូមថ្លែងអំណរគុណជាអនេកចំពោះគ្រប់ក្រសួង-ស្ថាប័ននានានៅក្នុងវិស័យសាធារណៈ និងឯកជន ព្រមទាំងដៃគូអភិវឌ្ឍន៍ទាំងអស់ដែលបានគាំទ្រនិងរួមចំណែកនៅក្នុងសមិទ្ធផលនេះ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងនាងកញ្ញា ឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។ ខ្ញុំសូមឱ្យអង្គសន្និបាតរបស់យើងប្រព្រឹត្តទៅប្រកបដោយជោគជ័យ និងផ្លែផ្កា។

**ខ្ញុំសូមប្រកាសបើកអង្គសន្និបាតជាផ្លូវការចាប់ពីពេលនេះតទៅ។**

**សូមអរគុណ!**

ថថថ*ឥឥឥ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៧ របស់ធនាគារជាតិនៃកម្ពុជា
## សាលពិព័រណ៍កោះពេជ្រ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៧

**សូមគោរព៖**

**សូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !**

នាពេលនេះ សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៧ របស់ធនាគារជាតិនៃកម្ពុជា បានឈានដល់ទីបញ្ចប់ហើយ។ ជារួម ខ្ញុំមានមោទនភាពជាអនេក និងសូមវាយតម្លៃខ្ពស់ថា សន្និបាតរបស់យើងបានប្រព្រឹត្តទៅប្រកបដោយជោគជ័យ ក្រោមបរិយាកាសសប្បាយរីករាយ សាមគ្គីភាព ភាតរភាព និងស្និទ្ធស្នាលជាទីបំផុតក្នុងនាមជាសមាជិកគ្រួសារធនាគារជាតិនៃកម្ពុជាតែមួយ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះថ្នាក់ដឹកនាំរបស់យើងដែលបានធ្វើបទបង្ហាញ និងបទអន្តរាគមន៍ និងសូមថ្លែងអំណរគុណចំពោះការចូលរួមយ៉ាងសកម្ម និងដោយការយកចិត្តទុកដាក់របស់សមាជិក-សមាជិកានៃអង្គសន្និបាតទាំងមូលក្នុងរយៈពេលពេញមួយថ្ងៃនេះ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !**

ផ្អែកលើសុទិដ្ឋិនិយមពីភាពអំណោយផលនៃស្ថានភាពសេដ្ឋកិច្ចពិភពលោក និងតំបន់និងសកម្មភាពរីកចម្រើនតាមវិស័យសេដ្ឋកិច្ចចម្បងៗ សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថាបន្តបោះជំហានទៅមុខយ៉ាងស្វាហាប់នៅឆ្នាំ២០១៧ ក៏ដូចជារយៈកាលមធ្យមខាងមុខក្នុងអត្រាប្រមាណ ៧%។ ទោះយ៉ាងណា សេដ្ឋកិច្ចកម្ពុជាក៏អាចប្រឈមនឹងបញ្ហាមួយចំនួនផងដែរ ដូចដែលថ្នាក់ដឹកនាំយើងបានធ្វើបទបង្ហាញកាលពីព្រឹកមិញ។ លើសពីនេះ នៅពេលដែលវិស័យធនាគាររីកចម្រើនជាលំដាប់ ជាពិសេសមានសមាហរណកម្មខ្ពស់ទៅក្នុងតំបន់បញ្ហាប្រឈមថ្មីៗក៏នឹងអាចកើតឡើងផងដែរ។

ក្នុងបរិការណ៍នេះ ដើម្បីបន្តរួមចំណែកគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការសម្រេចបានកំណើនប្រកបដោយចីរភាព សមភាព បរិយាប័ន្ន និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ធនាគារជាតិនៃកម្ពុជានឹងបន្តលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ អភិវឌ្ឍវិស័យធនាគារប្រកបដោយប្រសិទ្ធភាពភាពរឹងមាំ ភាពប្រកួតប្រជែងនិងសមាហរណកម្មព្រមទាំងបន្តធ្វើទំនើបកម្មប្រព័ន្ធទូទាត់ និងបំពេញមុខងារធនាគារកណ្តាលចម្បងៗដទៃទៀតឱ្យមានប្រសិទ្ធភាព ដើម្បីឈានទៅសម្រេចបាននូវសមិទ្ធផលថ្មីៗបន្ថែមទៀតនាពេលខាងមុខ ស្របតាមយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ និងយុទ្ធសាស្រ្ត

ចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល។

ក្នុងទិសដៅនេះ ខ្ញុំសូមផ្តាំផ្ញើដល់សមាជិក-សមាជិកាទាំងអស់នូវការងារចម្បងៗដែលយើងត្រូវអនុវត្តបន្តនៅឆមាសទី២ ឆ្នាំ២០១៧នេះ ដូចតទៅ៖

**១. ការលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ** ៖ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងដែលយើងសម្រេចបានជាបន្តបន្ទាប់ ដើម្បីរួមចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយរូបិយវត្ថុក្នុងស្ថានភាពដែលសេដ្ឋកិច្ចកម្ពុជាប្រឈមនឹងដុល្លារូបនីយកម្មខ្ពស់។ ខ្ញុំសូមឯកភាពចំពោះ បទអន្តរាគមន៍របស់លោកជំទាវអគ្គនាយកបច្ចេកទេសនិងសូមស្នើឱ្យ ៖

- i/- បន្តអនុវត្តវិធានការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលជាលំដាប់ ផ្អែកលើទីផ្សារ និងសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំគោលនយោបាយថ្នាក់ជាតិ ដើម្បីជំរុញការប្រើប្រាស់ប្រាក់រៀលឱ្យបានទូលំទូលាយ
- ii/- បន្តអភិវឌ្ឍទីផ្សារអន្តរធនាគារនិងរូបិយវត្ថុ ដូចជាការជំរុញការប្រើប្រាស់មូលបត្រអាចជួញដូរបាន (NCDs) ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) និងឧបករណ៍ដទៃទៀត
- iii/- បន្តអភិវឌ្ឍទីផ្សារប្តូរប្រាក់ ដើម្បីស្រូបយករូបិយប័ណ្ណនិងផ្គត់ផ្គង់រូបិយវត្ថុទៅក្នុងចរាចរណ៍ឱ្យកាន់តែប្រសើរឡើង
- iv/- ដាក់ឱ្យដំណើរការផ្លែតហ្វមធនាគារជាតិនៃកម្ពុជា ឱ្យបានតាមកាលកំណត់ និង
- v/- បន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងការវិនិយោគទុនបម្រុងអន្តរជាតិ ដើម្បីគរពូនទុនបម្រុងឱ្យកើនឡើងជាលំដាប់ សំដៅរួមចំណែកពង្រឹងភាពធន់នៃសេដ្ឋកិច្ចជាតិ។

**២. ចំពោះការងារត្រួតពិនិត្យ** ៖ ខ្ញុំសូមឯកភាពនឹងមតិរបស់លោកអគ្គនាយករងត្រួតពិនិត្យលើការរីកចម្រើនក្នុងវិស័យធនាគារ។ យ៉ាងណាមិញ ក្នុងស្ថានភាពដែលទីផ្សារហិរញ្ញវត្ថុអន្តរជាតិស្ថិតក្នុងភាពមិនច្បាស់លាស់នៅឡើយ ហើយដើម្បីបន្តពង្រឹងស្ថិរភាពហិរញ្ញវត្ថុនិងតួនាទីរបស់វិស័យធនាគារក្នុងការគាំទ្រកំណើនសេដ្ឋកិច្ច ខ្ញុំសូមឱ្យអគ្គនាយកដ្ឋានត្រួតពិនិត្យ៖

- បន្តពង្រឹងការត្រួតពិនិត្យ ដោយផ្អែកលើហានិភ័យនិងទស្សនៈអនាគត ស្របតាមឧត្តមានុវត្តអន្តរជាតិ ជាពិសេសគោលការណ៍ស្នូលបាសែល
- បន្តលើកកម្ពស់ក្របខណ្ឌគតិយុត្តិនិងការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិងប្រតិបត្តិករ ឥណទានជនបទ សំដៅពង្រឹងស្ថិរភាពហិរញ្ញវត្ថុ ក៏ដូចជាបង្កើនគណនេយ្យភាព និងតម្លាភាពក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- បញ្ចប់ការចុះបញ្ជីប្រតិបត្តិករឥណទានដែលនៅសេសសល់
- តាមដានលើឥទ្ធិពលនៃការដាក់ចេញនូវគោលនយោបាយម៉ាក្រូ និងមីក្រូប្រុងប្រយ័ត្នកន្លងមក ដូចជាអនុបាតក្របខ័ណ្ឌសន្ទនីយភាព និងការដាក់ពិដានអត្រាការប្រាក់
- តាមដានលើវឌ្ឍនភាពនៃការដាក់ឱ្យប្រើប្រាស់ផលិតផលនិងសេវាហិរញ្ញវត្ថុថ្មីៗ ជាពិសេស បច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech)
- បន្តលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុឱ្យបានទូលំទូលាយនិងប្រកបដោយចីរភាពនិងបញ្ចប់ការរៀបចំយុទ្ធសាស្ត្របរិយាប័ន្នហិរញ្ញវត្ថុ

- លើកកម្ពស់ការអប់រំផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន
- បន្តការងារអភិវឌ្ឍន៍គម្រោងបង្កើតប្រព័ន្ធការពារប្រាក់បញ្ញើ និង
- បន្តពិនិត្យនិងកែលម្អប្រកាសនិងបទប្បញ្ញត្តិដែលមានស្រាប់និងរៀបចំប្រកាសនិងបទប្បញ្ញត្តិថ្មីៗ បន្ថែមទៀតឱ្យស្របទៅនឹងការអភិវឌ្ឍនៃវិស័យធនាគារ។

**៣. ចំពោះការផ្តល់សេវាធនាគារកណ្តាល៖** ក្នុងនាមជាអ្នកផ្តល់សេវាធនាគារកណ្តាលដល់ស្ថាប័នរដ្ឋក៏ដូចជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនានា ខ្ញុំសូមឱ្យមន្ត្រីយើងបន្តពង្រឹងគុណភាពនៃការផ្តល់សេវាតាមរយៈការទទួលអតិថិជនដោយរាក់ទាក់ និងទឹកមុខញញឹមរីករាយទាំងនៅស្នាក់ការកណ្តាល និងនៅតាមសាខារាជធានី-ខេត្ត សំដៅសម្រួលប្រតិបត្តិការឱ្យមានប្រសិទ្ធភាព និងកសាងជំនឿទុកចិត្តមកលើធនាគារជាតិនៃកម្ពុជា។

ចំពោះការងារគ្រប់គ្រងប្រព័ន្ធទូទាត់ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះការធ្វើទំនើបកម្មប្រព័ន្ធទូទាត់ ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យា។ ទន្ទឹមនេះ ខ្ញុំសូមស្នើឱ្យអគ្គនាយកដ្ឋានបច្ចេកទេស ៖

i/- ដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ Cambodian Shared Switch សម្រាប់សម្រួលដល់ប្រតិបត្តិការទូទាត់អន្តរធនាគារជាមួយនឹងចំណាយប្រតិបត្តិការទាប

ii/- បន្តអភិវឌ្ឍប្រព័ន្ធទូទាត់ដុលភ្លាមៗ (RTGS) ដើម្បីសម្រួលដល់ប្រតិបត្តិការទូទាត់ ដែលមានតម្លៃធំ និង

iii/- បន្តសហការជាមួយក្រុមការងារធនាគារពិភពលោក ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់។

**៤. ការពង្រឹងសុវត្ថិភាពបច្ចេកវិទ្យា៖** នៅក្នុងយុគសម័យបច្ចេកវិទ្យាព័ត៌មានធនាគារជាតិនៃកម្ពុជាបានប្រើប្រាស់បច្ចេកទេស ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារនិងបានការពារហានិភ័យបច្ចេកទេសយ៉ាងរឹងមាំ។ ដើម្បីបន្តពង្រឹងការពារសុវត្ថិភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងវិស័យធនាគារ ប្រកបដោយប្រសិទ្ធភាព ខ្ញុំសូមផ្តាំឱ្យអគ្គលេខាធិការដ្ឋាន ៖

i/- ពង្រឹងការអនុវត្តគោលនយោបាយសុវត្ថិភាពបច្ចេកវិទ្យា

ii/- សហការជាមួយនាយកដ្ឋានពាក់ព័ន្ធក្នុងការធ្វើស្វ័យប្រវត្តិកម្មមូលដ្ឋានទិន្នន័យ និងពង្រឹងការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ និង

iii/- សិក្សាលើការធ្វើទំនើបកម្មបច្ចេកវិទ្យាដើម្បីប្រើប្រាស់ក្នុងប្រតិបត្តិការធនាគារកណ្តាល។

**៥. ចំពោះការគ្រប់គ្រងចរាចរសាច់ប្រាក់៖** ស្ថិតក្នុងសេដ្ឋកិច្ចដែលពឹងផ្អែកលើសាច់ប្រាក់ច្រើនជាពិសេសក្នុងសេដ្ឋកិច្ចដុល្លារូបនីយកម្ម ការគ្រប់គ្រង និងផ្គត់ផ្គង់រូបិយវត្ថុក្នុងចរាចរណ៍មានសារៈសំខាន់ណាស់ចំពោះការពង្រឹងជំនឿទុកចិត្តមកលើប្រាក់រៀល។ កន្លងមកអគ្គបេឡាបានសម្រេចការងារគ្រប់គ្រងចរាចរប្រាក់រៀលយ៉ាងល្អប្រសើរ ហើយជាលទ្ធផលបានរួមចំណែកគាំទ្រការរីកចម្រើនសកម្មភាពសេដ្ឋកិច្ច និងជំរុញការប្រើប្រាស់ប្រាក់រៀលជាលំដាប់។ ខ្ញុំសូមគាំទ្រមតិរបស់ឯកឧត្តមអគ្គបេឡាដែលបានលើកឡើងនិងសូមស្នើឱ្យ៖

i/-បន្តគ្រប់គ្រងចរាចរណ៍រូបិយវត្ថុដោយផ្គត់ផ្គង់ទៅតាមតម្រូវការ និងឱ្យបានទាន់ពេលវេលាស្របតាមការរីកចម្រើននៃស្ថានភាពសេដ្ឋកិច្ចនៅតាមតំបន់ និង

ii/- បន្តពង្រឹងការយកចិត្តទុកដាក់ជាប្រចាំលើការគ្រប់គ្រង ថែរក្សានិងធានាការពារសុវត្ថិភាព ឃ្លាំងប្រាក់។

**៦. ចំពោះការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ៖** ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធនិងប្រសិទ្ធភាពក្នុងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ ទន្ទឹមនេះ ខ្ញុំសូមស្នើឱ្យអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា៖

i/- តាមដានលទ្ធផលការវាយតម្លៃអញ្ញមញ្ញ និងផែនការសកម្មភាពកែតម្រូវ

ii/- បន្តលើកកម្ពស់ការយល់ដឹងរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុស្តីពីហានិភ័យការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និង

iii/- ពង្រឹងសមត្ថភាពវិភាគប្រតិបត្តិការ និងការត្រួតពិនិត្យបុគ្គលរាយការណ៍ជាបន្តបន្ទាប់។

**៧. ចំពោះការពង្រឹងអភិបាលកិច្ច** ៖ ខ្ញុំសូមឯកភាព ចំពោះមតិរបស់លោកជំទាវអគ្គពិនិត្យដែលថាការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ចមានសារៈសំខាន់ណាស់ចំពោះការលើកកម្ពស់អភិបាលកិច្ចល្អ ដែលជាលក្ខខណ្ឌចាំបាច់ ដើម្បីសម្រេចបាននូវប្រសិទ្ធភាព និងវឌ្ឍនភាពការងារ។ ដើម្បីបន្តលើកកម្ពស់អភិបាលកិច្ចល្អ ខ្ញុំសូមស្នើឱ្យ៖

i/- បន្តអនុវត្តសវនកម្មនៅតាមសវនដ្ឋានដែលបានចែងនៅក្នុងផែនការឆ្នាំ២០១៧

ii/- តាមដានការអនុវត្តអនុសាសន៍ដែលបានផ្តល់ដល់សវនដ្ឋាន

iii/- ពង្រឹងការវាយតម្លៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងជាពិសេសការគ្រប់គ្រងហានិភ័យប្រព័ន្ធធនាគារស្នូល និង

iv/- ធ្វើអធិការកិច្ចនៅតាមបណ្តានាយកដ្ឋាននិងអង្គភាពផ្សេងៗក្រោមឱវាទ។ ទន្ទឹមនេះ ខ្ញុំសូមឯកភាពលើមតិណែនាំរបស់ឯកឧត្តមអគ្គបេឡា ចំពោះការបន្តពង្រឹងវិន័យការងារនិងសាមគ្គីភាពផ្ទៃក្នុងរបស់មន្ត្រីបុគ្គលិកសំដៅរួមចំណែកពង្រឹងអភិបាលកិច្ច និងប្រសិទ្ធភាពការងារ។ ខ្ញុំសូមស្នើឱ្យគ្រប់នាយកដ្ឋាននិងអង្គភាពក្រោមឱវាទទាំងអស់បន្តរក្សានូវវិន័យ ការងារឱ្យបានម៉ឺងម៉ាត់ ភាពស្មោះត្រង់និងស្មារតីសាមគ្គីជាប្រពៃណីឱ្យបានខ្ជាប់ខ្ជួន ដើម្បីសម្រេចបានសមិទ្ធផលការងារតាមការគ្រោងទុក។

**៨. ចំពោះប្រតិបត្តិការរបស់សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត៖**

ដូចដែលលោកអគ្គលេខាធិការបានធ្វើបទអន្តរាគមន៍រួចហើយ
សៀវភៅក្រហមគឺជាឯកសារណែនាំ ស្តីពីប្រតិបត្តិការរបស់សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ក្នុងគោលបំណងបំពេញតម្រូវការចាំបាច់ ដើម្បីអនុវត្តប្រតិបត្តិការការងារឱ្យបានរលូនត្រឹមត្រូវ រហ័សទាន់ពេលវេលានិងមានសង្គតិភាព។ ខ្ញុំសូមកោតសរសើរចំពោះគណៈកម្មការធ្វើបច្ចុប្បន្នកម្មសៀវភៅក្រហម ដែលបានខិតខំពិនិត្យយ៉ាងហ្មត់ចត់ដល់ការរៀបចំធ្វើបច្ចុប្បន្នកម្មសៀវភៅនេះ។ ដោយសារការរីកចម្រើននៃទំហំការងារជាលំដាប់ ខ្ញុំសូមស្នើឱ្យអគ្គលេខាធិការដ្ឋាន ៖

i/- ប្រើប្រាស់ឯកសារនេះជាបន្ទាត់ការងារដែលមន្ត្រី-បុគ្គលិកត្រូវអនុវត្តតាម ជៀសវាងការអនុវត្តការងារមិនមានសង្គតិភាព

ii/- បន្តរៀបចំវគ្គបណ្តុះបណ្តាលចែករំលែកចំណេះដឹង និងបទពិសោធន៍ថ្មីៗពីប្រព័ន្ធធនាគារស្នូល

iii/- និងនីតិវិធីការងារក្នុងសៀវភៅក្រហមថ្មីនេះ ជាពិសេសដល់មន្ត្រីធ្វើប្រតិបត្តិការផ្ទាល់នៅតាមបណ្តាសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត និង

iv/- លើកកម្ពស់ការតាមដានភាពរីកចម្រើន និងស្ថានភាពសេដ្ឋកិច្ចតាមបណ្តារាជធានី-ខេត្ត និងបន្តកិច្ចសហការល្អជាមួយស្ថាប័ន-មន្ទីរនានា។

**៩. ការងារគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានមនុស្ស** ៖ នៅក្នុងយុគសម័យសេដ្ឋកិច្ចពុទ្ធិឧត្តមភាពប្រកួតប្រជែងរបស់ប្រទេសមួយ គឺអាស្រ័យជាសំខាន់លើកត្តាធនធានមនុស្ស ដែលមានចំណេះដឹង និងជំនាញ

ច្បាស់លាស់។ ខ្ញុំសង្កេតឃើញថា សមត្ថភាពធនធានមនុស្សមានការរីកចម្រើនគួរឱ្យកត់សម្គាល់ពីមួយឆ្នាំទៅមួយឆ្នាំនិងសូមឯកភាពលើរបាយការណ៍របស់ ឯកឧត្តមទេសាភិបាលរង និងសូមកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់មន្ត្រីបុគ្គលិកយើងដែលបានអភិវឌ្ឍចំណេះដឹងនិងបទពិសោធន៍របស់ខ្លួនជាប្រចាំ។ ស្របតាមទំហំការងារដែលរីកធំធាត់ជាលំដាប់ ធនាគារជាតិនៃកម្ពុជានឹងបន្តកំណត់យកការអភិវឌ្ឍសមត្ថភាពធនធានមនុស្សជាការងារអាទិភាពដ៏សំខាន់។ ក្នុងស្មារតីនេះ ខ្ញុំសូមគាំទ្រទិសដៅការងារដែលបានលើកឡើងដោយឯកឧត្តមទេសាភិបាលរងនិង សូមស្នើឱ្យអគ្គលេខាធិការដ្ឋាន៖

- i/- បន្តរក្សាវប្បធម៌ចែករំលែកបទពិសោធន៍តាមយន្តការផ្ទៃក្នុង ដូចជា ការរៀបចំវគ្គបណ្តុះបណ្តាលនានានិងការចែករំលែកចំណេះដឹងនិងបទពិសោធន៍ រវាងមន្ត្រីបុគ្គលិកនៅក្នុងនាយកដ្ឋាន និងអង្គភាព
- ii/- បន្តលើកទឹកចិត្ត និងសម្រិតសម្រាំងមន្ត្រី-បុគ្គលិកក្នុងការបន្តការសិក្សាឬវគ្គបណ្តុះបណ្តាលរយៈពេលខ្លី និងវែងនៅក្រៅប្រទេស
- iii/- ពង្រឹងរចនាសម្ព័ន្ធចាត់តាំងមន្ត្រីបុគ្គលិកស្របតាមគោលនយោបាយយុទ្ធសាស្ត្រ និងតម្រូវការការងារជាក់ស្តែងនិង
- iv/- រៀបចំយន្តការនិងក្របខ័ណ្ឌវាយតម្លៃលទ្ធផលការងាររបស់មន្ត្រី-បុគ្គលិក ដើម្បីជាមូលដ្ឋានក្នុងការបែងចែកការងារ ការលើកទឹកចិត្ត ក៏ដូចជាអភិវឌ្ឍចំណេះដឹងបន្ថែម សំដៅធានាឱ្យបានគុណភាពនិងប្រសិទ្ធភាពការងារ។

**១០.ចំពោះការងារសមាគមមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា៖** កន្លងមកគណៈកម្មាធិការសមាគមមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា បានដើរតួនាទីសំខាន់ក្នុងការជួយរួមចំណែកសម្រាលទុក្ខលំបាករបស់សមាជិក និងគ្រួសារសមាជិកដែលជួបប្រទះនឹងជំងឺធ្ងន់ធ្ងរ និងមរណភាព។ ការជួយគ្នានេះ បានពង្រឹងសាមគ្គីភាពយ៉ាងកក់ក្តៅរវាងមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាយើង។ ខ្ញុំសូមឯកភាព លើរបាយការណ៍របស់លោកជំទាវ អគ្គពិនិត្យនិងសូមស្នើឱ្យបន្តប្រកាន់យកស្មារតីរួបរួមសាមគ្គីគ្នានេះបន្តទៀតនិងសូមស្នើ ៖

- i/- ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌនៃការផ្តល់ប្រាក់ឧបត្ថម្ភដល់សមាជិកឱ្យកាន់តែច្បាស់ ដើម្បីជៀសវាងការប្រើប្រាស់ថវិកាសមាគមខុសគោលដៅ និង
- ii/- បន្តពង្រឹងការគ្រប់គ្រង និងប្រើប្រាស់មូលនិធិរបស់សមាគមឱ្យបានត្រឹមត្រូវប្រកបដោយប្រសិទ្ធភាពខ្ពស់។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ខ្ញុំជឿជាក់ថា សមាជិក-សមាជិកាអង្គសន្និបាតរបស់យើងពិតជាក្តាប់បាននូវខ្លឹមសារសំខាន់ៗនៃសមិទ្ធផលការងារ និងទិសដៅ ដែលលើកឡើងក្នុងអង្គសន្និបាត។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំក៏សូមលើកយកសង្គហធម៌បួនដែលជាធម៌សម្រាប់សង្គ្រោះដល់គ្នានឹងគ្នាមកជម្រាបជូនអង្គសន្និបាត ដើម្បីជាគតិ ៖

**ទី១ គឺ ទានៈ៖** ការចែករំលែកឱ្យចំពោះបុគ្គល ក្រុម និងសង្គមជាតិ។ ទានៈចែកចេញជា២គឺ៖

- i/- អសាធារណទាន គឺបរិច្ចាគ ឬតបគុណចំពោះរូបបុគ្គលណាម្នាក់ដូចជាចំពោះមាតាបិតា កូនចៅចៅហ្វាយនាយ គ្រូបាធ្យាយ និងចាស់ព្រឹទ្ធាចារ្យ
- ii/- សាធារណទាន គឺជាទានដែលអាចឱ្យសេចក្តីសុខដ៏ធំទូលាយមិនចំពោះតែបុគ្គលណាម្នាក់ ដូចជាការសាងសង់សាលា ស្ពាន ការដាំដើមឈើ ជាដើម។

**ទី២ គឺ បេយ្យវជ្ជៈ** ៖ គឺការពោលពាក្យពិរោះគួរឱ្យជាប់ចិត្តដែលក្នុងនាមយើងជាស្ថាប័នផ្តល់សេវាត្រូវប្រព្រឹត្តឱ្យបានខ្ជាប់ខ្ជួន ដើម្បីពង្រឹងជំនឿទុកចិត្តរបស់សាធារណជន។ បេយ្យវជ្ជៈចែកចេញជា២គឺ៖

i/- បិយវាចា = វាចាទន់ភ្លន់គួរជាទីស្រលាញ់ដល់អ្នកស្តាប់

ii/- អត្ថសញ្ហិតាវាចា = វាចាប្រកបដោយប្រយោជន៍ ជាសម្តីមានតម្លៃ ហើយអ្នកស្តាប់ដែលប្រតិបត្តិតាមរមែងកើតជាផលប្រយោជន៍។ សំដីយ៉ាងនេះ ចាត់ជាសំដីបានការ ជាសំដីអ្នកប្រាជ្ញ។

**ទី៣ គឺ អត្ថចរិយា** ៖ កិរិយាប្រព្រឹត្តជាប្រយោជន៍ដល់គ្នានឹងគ្នាគឺមានសារៈសំខាន់ក្នុងការជួយគ្នាទៅវិញទៅមកក្នុងការងារ។ ការឱ្យទាននិងការនិយាយពាក្យពិរោះជាគុណដែលបណ្តាលឱ្យមានក្តីស្រលាញ់ក៏មែនពិត ប៉ុន្តែបើជាមនុស្សចេះតែមើលបំណាំគ្នាទៅវិញទៅមកមិនប្រព្រឹត្តប្រយោជន៍ដល់គ្នា នោះការជិតស្និទ្ធក៏នឹងសាបរលាបទៅវិញបានដោយងាយ។ ព្រោះហេតុនេះ អត្ថចរិយា ការប្រព្រឹត្តជាប្រយោជន៍ដល់គ្នាទៅវិញទៅមក ក៏ជាគុណយ៉ាងសំខាន់អាចយឹតយោងគ្នាឱ្យទៅកាន់សេចក្តីសុខចម្រើនតទៅបាន។

**ទី៤ គឺ សមានត្តតា** ៖ ភាពជាអ្នកតាំងខ្លួនឱ្យស្មោះស្មើទៅរកបុគ្គលផងគ្នា។ ទោះជាការឱ្យទាននិយាយពិរោះ ឬធ្វើប្រយោជន៍ឱ្យគ្នា ពិតជានាំមកនូវសេចក្តីសុខ តែបើមិនចេះរៀបចំខ្លួនប្រាណឱ្យបានសមរម្យគឺមិនស្គាល់ធំ-តូច-ខ្ពស់-ទាប ជាអ្នកប្រកាន់ មានៈ ក្អេងក្អាង មើលងាយគេ ធ្វើឫកពាក្រអឺតក្រអោង សេចក្តីរាប់អានគ្នាក៏នឹងសាបរលាបទៅវិញ។ លុះត្រាតែយើងរក្សាបាននូវសេចក្តីស្មោះតាំងខ្លួនឱ្យសមរម្យទើបសេចក្តីរាប់អាននោះនឹងមានកម្លាំងអាចតាំងនៅយូរអង្វែងបាន។

សង្គហធម៌ទាំង៤យ៉ាងនេះ តែងណែនាំមនុស្សទាំងអស់ឱ្យមូលមិត្រគ្នាក្នុងសកលលោក។ បើសង្គហធម៌នេះមិនមានហើយសាមគ្គីគឺការព្រមព្រៀងមូលមិត្រគ្នាក៏នឹងធ្លុះធ្លាយបែកបាក់ទៅពុំខាន។

ជាថ្មីម្តងទៀត ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសមាជិកក្រុមប្រឹក្សាភិបាល មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ ក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍនានាដែលបានខិតខំរួមចំណែកកសាងសមិទ្ធផលយ៉ាងច្រើន សម្រាប់ពង្រឹងនិងអភិវឌ្ឍប្រព័ន្ធធនាគារនៅកម្ពុជាឱ្យមានការរីកចម្រើនសំដៅគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះ លោកជំទាវ ឯកឧត្តម លោក លោកស្រីនាងកញ្ញា ដែលបានអញ្ជើញចូលរួមក្នុងអង្គសន្និបាត និងសូមជូនពរឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**ខ្ញុំសូមប្រកាសបិទអង្គសន្និបាតរបស់យើងជាស្ថាពរ ។**

**សូមអរគុណ!**

# អត្ថបទស្រាវជ្រាវ
# ស្តីពីទុនបម្រុងអន្តរជាតិ

## នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ នៃធនាគារជាតិនៃកម្ពុជា

ទុនបម្រុងអន្តរជាតិដើរតួនាទីយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ច ដោយអនុញ្ញាតឱ្យធនាគារកណ្តាលមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងអត្រាប្តូរប្រាក់ ដោះស្រាយបញ្ហាជញ្ជីងទូទាត់ ពង្រឹងស្ថិរភាពវិស័យហិរញ្ញវត្ថុ និងជំនឿទុកចិត្តរបស់ប្រទេស ព្រមទាំងគរពូនទ្រព្យសម្បត្តិជាតិ។ ដើម្បីអនុវត្តកិច្ចការនេះប្រកបដោយប្រសិទ្ធភាព ធនាគារកណ្តាលត្រូវមានទុនបម្រុងអន្តរជាតិក្នុងកម្រិតគ្រប់គ្រាន់ស្របតាមស្ថានភាពសេដ្ឋកិច្ច ជាពិសេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ដោយសារការទទួលបានប្រភពរូបិយប័ណ្ណបរទេសពីខាងក្រៅនៅមានកម្រិត និងសម្រាប់ប្រទេសដែលប្រកាន់របបអត្រាប្តូរប្រាក់ថេរ គឺតម្រូវឱ្យមានរូបិយប័ណ្ណបរទេសគ្រប់គ្រាន់ដើម្បីធ្វើអន្តរាគមន៍ក្នុងទីផ្សារប្តូរប្រាក់។

## I. ទុនបម្រុងអន្តរជាតិ

យោងតាមមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)[1] ទុនបម្រុងអន្តរជាតិរបស់ប្រទេសមួយសំដៅលើ "ទ្រព្យសកម្មខាងក្រៅទាំងឡាយណាដែលមានសន្ទនីយភាពខ្ពស់ ហើយត្រូវបានគ្រប់គ្រងដោយអាជ្ញាធររូបិយវត្ថុសម្រាប់បំពេញតម្រូវការហិរញ្ញប្បទានដល់ជញ្ជីងទូទាត់ ធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ដើម្បីគ្រប់គ្រងនិងរក្សាស្ថិរភាពអត្រាប្តូរប្រាក់និងសម្រាប់ប្រើប្រាស់ក្នុងគោលបំណងផ្សេងៗទៀត ដូចជា ការរក្សាជំនឿទុកចិត្តលើរូបិយវត្ថុនិងស្ថានភាពសេដ្ឋកិច្ចជាតិ និងការធ្វើជាមូលដ្ឋានសម្រាប់ការខ្ចីបំណុលពីបរទេស"។ ទុនបម្រុងអន្តរជាតិរាប់បញ្ចូល មាស ទ្រព្យសកម្មជារូបិយប័ណ្ណបរទេស (សាច់ប្រាក់ក្នុងបេឡា ប្រាក់បញ្ញើ និងសញ្ញាប័ណ្ណជាដើម) ប្រាក់អេសដេអ៊ែរ (SDR)[2] និងទុនបម្រុងជាមួយ IMF (reserve position with the IMF)។

### ទុនបម្រុងអន្តជាតិអាចត្រូវបានបែងចែកជា ៣ ប្រភេទ ដូចជា៖

១/. ទុនបម្រុងអន្តរជាតិដុល (gross international reserves)៖ រួមមាន សាច់ប្រាក់ជារូបិយប័ណ្ណបរទេសក្នុងបេឡាធនាគារកណ្តាល មាស ប្រាក់អេសដេអ៊ែរ ទុនបម្រុងវិនិយោគក្រៅប្រទេស ប៉ុន្តែមិនរាប់បញ្ចូលប្រាក់បញ្ញើជារូបិយប័ណ្ណរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលដាក់ជាគណនីចរន្ត និងគណនីទូទាត់នៅធនាគារកណ្តាលនោះទេ។

---

[1] នៅក្នុងរបាយការណ៍ស្តីពីវិធីសាស្ត្រចងក្រងស្ថិតិជញ្ជីងទូទាត់ បោះពុម្ពលើកទី៦ (BPM6)

[2] SDR គឺជាទ្រព្យសកម្មទុនបម្រុងអន្តរជាតិមួយដែលត្រូវបានបង្កើតឡើងដោយ IMF នៅឆ្នាំ១៩៦៩ ដើម្បីបំពេញបន្ថែមដល់ទុនបម្រុងអន្តរជាតិរបស់ប្រទេសជាសមាជិក។ SDR អាចប្តូរជាមួយរូបិយប័ណ្ណនានាដោយសេរី ហើយតម្លៃរបស់វាគឺផ្អែកលើក្រុមរូបិយប័ណ្ណធំ ៥ គឺ ប្រាក់ដុល្លារ អឺរ៉ូ ផោន យ៉េន និងយ៉ន់ (ប្រាក់យ៉ន់ត្រូវបានរាប់បញ្ចូលនៅក្នុង SDR basket ចាប់ពីខែតុលា ឆ្នាំ២០១៦មក)។ គិតត្រឹមខែកញ្ញា ឆ្នាំ២០១៧នេះ SDR ចំនួន ២០៤,២ ប៊ីលាន (ប្រមាណ ២៩១ ប៊ីលានដុល្លារអាមេរិក) ត្រូវបានបង្កើត ហើយត្រូវបានបែងចែកឱ្យប្រទេសជាសមាជិកផ្អែកតាមចំនួនកូតារបស់ប្រទេសសមាជិកនីមួយៗ។

២/. ទុនបម្រុងអន្តរជាតិសុទ្ធ (net international reserve)៖ គឺស្មើនឹងទុនបម្រុងអន្តរជាតិដុលដកបំណុលបរទេស (ដូចជា កម្ចីពីស្ថាប័នហិរញ្ញវត្ថុឬធនាគារកណ្តាលបរទេស)។

៣/. ទុនបម្រុងវិនិយោគក្រៅប្រទេស (foreign reserve investment)៖ គឺជាទ្រព្យសកម្មគិតជារូបិយប័ណ្ណបរទេស ដែលធនាគារកណ្តាលអាចយកទៅវិនិយោគ ឬរក្សាទុកជាប្រាក់បញ្ញើជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ធនាគារកណ្តាលនៃប្រទេសអភិវឌ្ឍន៍ធំៗ និងគ្រឹះស្ថានធនាគារពាណិជ្ជដែលមានស្តង់ដារ និងចំណាត់ថ្នាក់វិនិយោគ (credit rating) ខ្ពស់។

## II. ប្រភពនៃការគរពូនទុនបម្រុងអន្តរជាតិ

ជាទូទៅ រូបិយប័ណ្ណបរទេសអាចហូរចូលក្នុងសេដ្ឋកិច្ចប្រទេសមួយតាមមធ្យោបាយជាច្រើន ដូចជា តាមរយៈពាណិជ្ជកម្មអន្តរជាតិ ការវិនិយោគពីបរទេស ភ្ញៀវទេសចរបរទេស ជំនួយ និងកម្ចីពីក្រៅប្រទេសជាដើម។ លំហូរចូលនៃរូបិយប័ណ្ណបរទេសទាំងនោះ ត្រូវហូរចូលក្នុងប្រព័ន្ធធនាគារ តាមរយៈការប្តូរយករូបិយវត្ថុក្នុងស្រុក ឬការដាក់ប្រាក់បញ្ញើ ហើយនៅទីបញ្ចប់ មួយផ្នែកនៃរូបិយប័ណ្ណបរទេសនឹងត្រូវបានស្រូបយកដោយធនាគារកណ្តាល ដែលនឹងធ្វើឱ្យទុនបម្រុងអន្តរជាតិកើនឡើង។ បរិមាណទុនបម្រុងអន្តរជាតិមានការប្រែប្រួល អាស្រ័យលើការអនុវត្តគោលនយោបាយរូបិយវត្ថុរបស់ធនាគារកណ្តាល ជាពិសេស តាមរយៈការធ្វើអន្តរាគមន៍ក្នុងទីផ្សារប្តូរប្រាក់ ដើម្បីរក្សាតម្លៃរូបិយវត្ថុជាតិឱ្យមានស្ថិរភាព ឬប្រែប្រួលក្នុងកម្រិតសមស្រប។ បន្ថែមពីនេះ ការគ្រប់គ្រងទុនបម្រុងអន្តរជាតិរបស់ធនាគារកណ្តាលប្រកបដោយប្រសិទ្ធភាពក៏បានរួមចំណែកយ៉ាងសំខាន់ដល់ការគរពូនទុនបម្រុងអន្តរជាតិ តាមរយៈការទទួលបានចំណូលពីការវិនិយោគក្រៅប្រទេសដូចជា ចំណូលការប្រាក់ ការកើនឡើងនៃតម្លៃរូបិយប័ណ្ណបរទេសនិងការឡើងថ្លៃនៃទ្រព្យសកម្មជាដើម។

ដើម្បីយល់ច្បាស់ពីប្រភពនៃការគរពូនទុនបម្រុងអន្តរជាតិ ការវិភាគអាចផ្អែកលើសមីការនៃស្ថិតិជញ្ជីងទូទាត់ ដូចខាងក្រោម៖

$$\textit{សមតុល្យគណនីចរន្ត} + \textit{សមតុល្យគណនីដើមទុននិងហិរញ្ញវត្ថុ} = -\textit{បម្រែបម្រួលទុនបម្រុងអន្តរជាតិ}$$

សមីការខាងលើនេះបានបង្ហាញឱ្យឃើញថា ប្រភពចម្បងនៃការគរពូនទុនបម្រុងអន្តរជាតិរបស់ប្រទេសមួយអាចបណ្តាលមកពី៖ អតិរេកនៃគណនីចរន្ត អតិរេកនៃគណនីដើមទុននិងហិរញ្ញវត្ថុ ឬអតិរេកនៃគណនីទាំងពីរនេះ (ដូចជាករណីប្រទេសចិន)។ សមតុល្យគណនីចរន្ត រួមមាន សមតុល្យគណនីទំនិញនិងសេវា គណនីចំណូល និងគណនីបង្វែរ (ដូចជា ការប្រាក់ ផ្ញើប្រាក់សម្រាប់ទ្រទ្រង់គ្រួសារ)។ ចំណែកឯសមតុល្យគណនីដើមទុននិងហិរញ្ញវត្ថុ រាប់បញ្ចូលនូវសមតុល្យគណនីដើមទុននិងគណនីហិរញ្ញវត្ថុ (ការវិនិយោគផ្ទាល់បរទេស ការវិនិយោគលើផលបត្រ និងការវិនិយោគផ្សេងៗទៀត)។ ដូច្នេះ ប្រទេសមួយដែលទទួលបានលំហូរសាច់ប្រាក់ពីបរទេសច្រើនជាងការចំណាយ ដូចជាការនាំចេញច្រើនជាងការនាំចូល (អតិរេកគណនីចរន្ត) ឬទទួលបានលំហូរមូលធនពីបរទេសច្រើន (អតិរេកគណនីដើមទុននិងហិរញ្ញវត្ថុ) នឹងអនុញ្ញាតឱ្យធនាគារកណ្តាលគៀរគរទុនបម្រុងអន្តរជាតិកាន់តែច្រើន ដោយសារធនាគារកណ្តាលអាចស្រូបយករូបិយប័ណ្ណបរទេសបានច្រើនពីក្នុងសេដ្ឋកិច្ច។

## III. គោលបំណងនៃការរក្សាទុកទុនបម្រុងអន្តរជាតិ

**មូលហេតុចម្បងៗដែលតម្រូវឱ្យធនាគារកណ្តាលរក្សាទុកទុនបម្រុងអន្តរជាតិ រួមមាន៖**

**១. ធានាឱ្យមានស្ថិរភាពអត្រាប្តូរប្រាក់**

ក្នុងនាមជាអាជ្ញាធររូបិយវត្ថុ ធនាគារកណ្តាលអាចធ្វើអន្តរាគមន៍ទីផ្សារប្តូរប្រាក់ តាមរយៈការទិញ ឬលក់រូបិយប័ណ្ណបរទេសដើម្បីរក្សាស្ថិរភាពអត្រាប្តូរប្រាក់ ព្រមទាំងធានាស្ថិរភាពថ្លៃ។ ជាការអនុវត្តជាក់ស្តែងក្នុងបរិបទសេដ្ឋកិច្ច ដែលមានកម្រិតដុល្លារូបនីយកម្មខ្ពស់ នៅពេលដែលតម្លៃប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកធ្លាក់ចុះ ធនាគារជាតិនៃកម្ពុជានឹងលក់ប្រាក់ដុល្លារទៅក្នុងទីផ្សារ ដើម្បីបញ្ចេញប្រាក់ដុល្លារអារមេរិក និងស្រូបយកប្រាក់រៀលពីទីផ្សារមកវិញ ដូច្នេះតម្លៃប្រាក់រៀលនឹងមានស្ថិរភាពឡើងវិញ។ ស្រដៀងគ្នានេះដែរ នៅពេលដែលតម្លៃប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកកើនឡើង ធនាគារជាតិនៃកម្ពុជានឹងទិញប្រាក់ដុល្លារដើម្បីបញ្ចេញប្រាក់រៀល។ ដូច្នេះ ដើម្បីធ្វើអន្តរាគមន៍ទីផ្សារប្តូរប្រាក់ ធនាគារកណ្តាលត្រូវពូនគរទុនបម្រុងអន្តរជាតិក្នុងបរិមាណសមស្រប ដើម្បីរក្សាជំនឿទុកចិត្តក្នុងការអនុវត្តគោលនយោបាយរបស់ខ្លួន។

ជាក់ស្តែង នៅខែកក្កដា ឆ្នាំ១៩៩៧ ប្រទេសថៃបានជួបវិបត្តិរូបិយវត្ថុ ហើយរាលដាលដល់ប្រទេសអាស៊ានផ្សេងទៀត ដូចជា ប្រទេសឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន និងកូរ៉េ ដែលបង្កឱ្យមានវិបត្តិហិរញ្ញវត្ថុនៅអាស៊ី។ ក្នុងរយៈពេលត្រឹមប្រាំសប្តាហ៍ ប្រាក់ថៃបាតបានធ្លាក់ថ្លៃដល់ទៅ ២០ ភាគរយ។ ដើម្បីរក្សាស្ថិរភាពអត្រាប្តូរប្រាក់ ធនាគារកណ្តាលថៃបានធ្វើអន្តរាគមន៍ក្នុងទីផ្សារប្តូរប្រាក់បរទេសដោយទិញប្រាក់ថៃបាតចំនួន ២០ ប៊ីលានដុល្លារអាមេរិក ដោយប្រើប្រាក់ទុនបម្រុងអន្តរជាតិទប់ទល់នឹងវិបត្តិនេះ ប៉ុន្តែនៅតែមិនអាចធ្វើឱ្យស្ថានភាពអត្រាប្តូរប្រាក់ប្រសើរឡើង ដោយសារប្រាក់បាតថៃធ្លាក់ថ្លៃខ្លាំង។ នៅខែសីហា ឆ្នាំដដែល មូលនិធិរូបិយវត្ថុអន្តរជាតិ និងប្រទេសមួយចំនួនសម្រេចផ្តល់មូលនិធិសង្គ្រោះជាកញ្ចប់សរុបចំនួន ១៧,២ ប៊ីលានដុល្លារអាមេរិក ដែលក្នុងនោះប្រទេសជប៉ុននិងមូលនិធិរូបិយវត្ថុអន្តរជាតិ បានផ្តល់មូលនិធិស្មើគ្នាចំនួន ៤ ប៊ីលានដុល្លារអាមេរិកដល់ប្រទេសថៃ។ ចំណែកប្រទេសដែលរងឥទ្ធិពលពីវិបត្តិនេះក៏ត្រូវការមូលនិធិសង្គ្រោះពីមូលនិធិរូបិយវត្ថុអន្តរជាតិ និងប្រទេសដទៃដែរ ដោយប្រទេសកូរ៉េទទួលបានសរុបចំនួន ៥៨,៤ ប៊ីលានដុល្លារអាមេរិក ឥណ្ឌូណេស៊ី ៤២,៣ ប៊ីលានដុល្លារអាមេរិក[3]។ ដោយឡែក ផលប៉ះពាល់នៃវិបត្តិនេះមានភាពខុសគ្នាចំពោះប្រទេសម៉ាឡេស៊ីនិងហ្វីលីពីន ដោយសារប្រទេសម៉ាឡេស៊ីមានស្ថានភាពម៉ាក្រូសេដ្ឋកិច្ចរឹងមាំ ខណៈដែលប្រទេសហ្វីលីពីនបានទទួលកម្មវិធីគាំទ្រការកែតម្រូវម៉ាក្រូសេដ្ឋកិច្ច និងការធ្វើកំណែទម្រង់បានទាន់ពេលវេលា ដូច្នេះឥទ្ធិពលដែលទទួលពីវិបត្តិនេះមានភាពធូរស្រាល[4]។

**២. ទូទាត់ទំនិញនាំចេញ-ចូលតាមរយៈជញ្ជីងទូទាត់**

ទុនបម្រុងអន្តរជាតិមានតួនាទីដើម្បីធានាថា ប្រទេសមួយអាចទូទាត់ប្រតិបត្តិការផ្សេងៗពីខាងក្រៅ រួមមាន ការទូទាត់បំណុលអន្តរជាតិ ដែលរួមបញ្ចូលទាំងបំណុលរដ្ឋាភិបាល និងបំណុលពាណិជ្ជកម្ម ការទូទាត់ទំនិញនាំចូលនិងលទ្ធភាពក្នុងការស្រូបយកមូលធនដែលមានចលនាមិនប្រាកដប្រជា។ ជាក់ស្តែង ការនាំចេញ-ចូលនៅប្រទេសអ៊ីស្លង់ (Iceland) ធ្លាប់មានការប្រែប្រួលខ្លាំង ដូច្នេះទុនបម្រុងអន្តរជាតិត្រូវបានប្រើប្រាស់ដើម្បីទូទាត់ទំនិញនាំចេញ-ចូលដើម្បីបង្ការការរំខាននៃការធ្វើពាណិជ្ជកម្មបរទេស។ ការរក្សាទុក

[3] IMF working paper, 1999

[4] Recovery from Asian Crisis and the Roles of IMF, 2000

ទុនបម្រុងអន្តរជាតិនេះ ប្រៀបដូចជាអាជីវកម្មដែលត្រូវការសន្ទនីយភាពគ្រប់គ្រាន់ក្នុងការទូទាត់ថ្លៃប្រតិបត្តិការប្រចាំថ្ងៃរបស់ខ្លួន។

ចំពោះប្រទេសចិន គណនីចរន្តនិងគណនីមូលធនមានអតិរេក (twin surpluses) ក្នុងរយៈពេល ២-៣ទសវត្សរ៍ ចុងក្រោយដោយសារការកើនឡើងនៃការនាំចេញនិងមានលំហូរចូលមូលធនក្នុងប្រទេស។ ដោយសារទំហំធំនៃអតិរេកក្នុងគណនីចរន្តនិងគណនីមូលធន ប្រទេសចិនបានពូនគរទុនបម្រុងអន្តរជាតិយ៉ាងច្រើន។ ទុនបម្រុងអន្តរជាតិនេះ បានកើនយ៉ាងខ្លាំងចាប់ពីឆ្នាំ២០០០មក ហើយមានចំនួន ៣,៨ ទ្រីលានដុល្លារអាមេរិកនៅឆ្នាំ២០១៤។ ទោះបីជាយ៉ាងណា អតិរេកនៃគណនីចរន្តនិងគណនីមូលធនបានចាប់ផ្តើមថយចុះក្នុងរយៈពេល១០ឆ្នាំចុងក្រោយ។ អតិរេកគណនីចរន្តបានថយចុះពី ៩,៩៤% នៃផ.ស.ស ដល់១,៧៥% នៃផ.ស.ស នៅឆ្នាំ២០០៧ និង២០១៦ រៀងគ្នា ប៉ុន្តែមូលធនមិនបានហូរចេញពីប្រទេសចិនទេ ទោះបីមានវិបត្តិសេដ្ឋកិច្ចនៅសហរដ្ឋអាមេរិក និងប្រទេសអភិវឌ្ឍន៍មួយចំនួនក៏ដោយ។ ទន្ទឹមនេះ នៅពេលដែលស្ថានភាពសេដ្ឋកិច្ចសកលមានស្ថិរភាពឡើងវិញ វិនិយោគិនបរទេសបានស្វែងរកឱកាសក្នុងការវិនិយោគនៅប្រទេសដទៃ ពិសេស នៅពេលដែលធនាគារកណ្តាលអាមេរិកបានប្រកាសពីការដំឡើងអត្រាការប្រាក់។ កត្តានេះរួមផ្សំនឹងអតិរេកគណនីចរន្តដែលមានកម្រិតទាប បានធ្វើឱ្យប្រាក់យ៉ន់ចិនចុះថ្លៃ ហើយបានបង្ខំឱ្យធនាគារកណ្តាលចិនលក់ទុនបម្រុងអន្តរជាតិដើម្បីការពារការធ្លាក់ថ្លៃយ៉ាងឆាប់រហ័សរបស់ប្រាក់យ៉ន់ចិន[5]។ ការណ៍នេះបានឆ្លុះបញ្ចាំងថា ការគរពូនទុនបម្រុងអន្តរជាតិពិតជាមានសារៈសំខាន់ណាស់ក្នុងការដោះស្រាយបញ្ហាចាំបាច់ផ្សេងៗ។

### ៣. ទុនបម្រុងអន្តរជាតិជាមូលដ្ឋានក្នុងការទទួលបានកម្ចីពីបរទេស

ទុនបម្រុងអន្តរជាតិជាមូលដ្ឋានក្នុងការទទួលបានកម្ចីពីបរទេស ដោយសារបរិមាណទុនបម្រុងអន្តរជាតិអាចធ្វើជាប៉ារ៉ាម៉ែត្រក្នុងការកំណត់ទំហំ និងតម្លៃកម្ចី។ ទុនបម្រុងនេះប្រៀបបាននឹងវត្ថុធានាក្នុងការផ្តល់កម្ចី។ ម្យ៉ាងទៀត ក្នុងកាលៈទេសៈដែលប្រទេសមួយមិនអាចសងបំណុលបាន ទុនបម្រុងអន្តរជាតិនឹងត្រូវបានប្រើប្រាស់ដើម្បីទូទាត់បំណុល។ ករណីវិបត្តិបំណុលនៅប្រទេសក្រិកបញ្ជាក់កាន់តែច្បាស់ពីភាពចាំបាច់ក្នុងការរក្សាទុកទុនបម្រុងអន្តរជាតិ។ នៅឆ្នាំ២០០១ ប្រទេសក្រិកបានបំពេញគ្រប់លក្ខខណ្ឌដើម្បីក្លាយជាសមាជិកតំបន់អឺរ៉ូ ហើយក្នុងអំឡុងពេល២-៣ឆ្នាំក្នុងការប្រើប្រាស់ប្រាក់អឺរ៉ូបានធ្វើឱ្យសេដ្ឋកិច្ចក្រិកមានភាពល្អប្រសើរ ព្រមទាំងទទួលបានផលប្រយោជន៍ពីការចូលជាសមាជិកនៃប្រទេសចាយប្រាក់អឺរ៉ូ ដូចជា អត្រាការប្រាក់ទាប ទាក់ទាញវិនិយោគ និងឥណទាន។ ប៉ុន្តែនៅឆ្នាំ២០០៤ ប្រទេសក្រិកបានប្រកាសថា ខ្លួនបានក្លែងបន្លំគុណវុឌ្ឍិក្នុងការក្លាយជាសមាជិកនៃប្រទេសចាយប្រាក់អឺរ៉ូ។ ជាលទ្ធផលបំណុលរបស់ប្រទេសក្រិកបានកើនឡើងជាលំដាប់ ដោយកម្រិតបំណុលធៀបនឹង ផ.ស.ស មានកម្រិត ១៧៩% ហើយឱនភាពថវិកា មានកម្រិត ១២,៩% ធៀបនឹង ផ.ស.ស ដែលជាសញ្ញាណនៃវិបត្តិធ្ងន់ធ្ងរនៅឆ្នាំ២០០៩។ ដើម្បីដោះស្រាយវិបត្តិនេះ ប្រទេសក្រិកបានប្រើប្រាស់ទុនបម្រុងអន្តរជាតិក្នុងការទូទាត់បំណុល ប៉ុន្តែមិនគ្រប់គ្រាន់សម្រាប់ទូទាត់បំណុលដ៏សន្ធឹកសន្ធាប់នោះទេ ដូច្នេះសហភាពអឺរ៉ុបនិងមូលនិធិរូបិយវត្ថុអន្តរជាតិបានផ្តល់មូលនិធិសង្គ្រោះចំនួន ២៤០ ប៊ីលានអឺរ៉ូ បន្ទាប់មកមានថវិកាសង្គ្រោះផ្សេងទៀតបានផ្តល់ដល់ប្រទេសក្រិកដើម្បីបន្តស្តារស្ថានភាពបំណុលនេះ[6]។

---

[5] Federal Reserve Bank of ST.Louis, 2017

[6] the balance, 2017

### ៤. ទប់ទល់នឹងហានិភ័យផ្សេងៗ

ទុនបម្រុងអន្តរជាតិ មានតួនាទីទប់ទល់នឹងហានិភ័យផ្សេងៗ ដូចជាការប្រែប្រួលខ្លាំងក្នុងគណនីចរន្ត គ្រោះមហន្តរាយធម្មជាតិនិងករណីដែលមានវិបត្តិសេដ្ឋកិច្ច។ ឧទាហរណ៍ នៅពេលដែលមានគ្រោះមហន្តរាយធម្មជាតិ ដូចជា ទឹកជំនន់ ឬការផ្ទុះភ្នំភ្លើង នឹងបង្កការរំខានដល់ការផលិតដើម្បីនាំចេញទៅក្រៅប្រទេស ដូច្នេះការផ្គត់ផ្គង់រូបិយប័ណ្ណបរទេសក្នុងការទូទាត់ទំនិញនាំចូលក៏មានឧបសគ្គដែរ។ ដើម្បីដោះស្រាយបញ្ហានេះ ទុនបម្រុងអន្តរជាតិនឹងត្រូវបានប្រើប្រាស់បណ្តោះអាសន្នក្នុងការទូទាត់ទំនិញ។ លើសពីនេះ ទុនបម្រុងអន្តរជាតិក៏បានរួមចំណែកកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាន និងបង្កើនទំនុកចិត្តដល់វិនិយោគិនបរទេសនៅពេលដែលមានលំហូរចេញមូលធនភ្លាមៗ។

## IV. សេចក្តីសន្និដ្ឋាន

ជារួម ការគរពូនទុនបម្រុងអន្តរជាតិពិតជាមានសារៈសំខាន់ណាស់នៅក្នុងសេដ្ឋកិច្ច ដោយសារធនាគារកណ្តាលអាចមានឧបករណ៍គ្រប់គ្រាន់ក្នុងការរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុនិងជាពិសេសការរក្សាបាននូវជំនឿទុកចិត្តមកលើរូបិយវត្ថុជាតិ។ បន្ថែមពីនេះ បរិមាណទុនបម្រុងអន្តរជាតិគ្រប់គ្រាន់ក៏បានរួមចំណែកពង្រឹងជំនឿទុកចិត្តពីគ្រប់ភ្នាក់ងារសេដ្ឋកិច្ចទាំងអស់ ជាពិសេសវិនិយោគិនជាតិនិងអន្តរជាតិ ហើយអាចធ្វើជាមូលដ្ឋានសម្រាប់ទាក់ទាញលំហូរមូលធន និងការវិនិយោគពីបរទេសដែលនឹងជួយជំរុញដល់ការបង្កើតការងារ និងគាំទ្រកំណើនសេដ្ឋកិច្ច។ កម្រិតរឹងមាំនៃទុនបម្រុងអន្តរជាតិក៏ជួយកាត់បន្ថយហានិភ័យរបស់ប្រទេសមួយ ដែលនឹងអនុញ្ញាតឱ្យរដ្ឋាភិបាលមានលទ្ធភាពខ្ចីបំណុលបរទេសក្នុងទំហំកាន់តែច្រើន ជាមួយអត្រាការប្រាក់ទាប។ ជាងនេះទៅទៀត ភាពគ្រប់គ្រាន់នៃទុនបម្រុងអន្តរជាតិនឹងជួយឱ្យអ្នករៀបចំគោលនយោបាយមានមធ្យោបាយគ្រប់គ្រាន់ក្នុងការដោះស្រាយឬកាត់បន្ថយឥទ្ធិពលឆ្លងរាលដាលនៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុពីខាងក្រៅមកលើសេដ្ឋកិច្ចជាតិបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព។

គួរបញ្ជាក់ផងដែរថា ការកើនឡើងនៃទុនបម្រុងអន្តរជាតិ ក៏បង្ហាញពីការកើនឡើងនៃបំណុលរបស់ធនាគារកណ្តាលផងដែរ ពោលគឺបរិមាណរូបិយវត្ថុជាតិនៅក្នុងចរាចរណ៍ និងប្រាក់បម្រុងរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលកំណត់ដោយបទប្បញ្ញត្តិ ដូចជាប្រាក់ធានាលើដើមទុន និងប្រាក់បម្រុងកាតព្វកិច្ចជាដើម។ ដូច្នេះ ធនាគារកណ្តាលចាំបាច់ត្រូវគ្រប់គ្រង និងវិនិយោគទុនបម្រុងអន្តរជាតិប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ ដើម្បីធានាដល់ការទូទាត់ឱ្យម្ចាស់បំណុល រួមមាន សាធារណជននិងវិនិយោគិន ក្នុងករណីដែលពួកគេចង់ដកយកទ្រព្យសកម្មរបស់ខ្លួនទៅរក្សាទុក ឬវិនិយោគនៅក្រៅប្រទេសវិញ។ ដើម្បីបង្ការនូវហានិភ័យនេះ ជាទូទៅទុនបម្រុងអន្តរជាតិត្រូវបានវិនិយោគដោយផ្អែកតាមគោលការណ៍លំដាប់អាទិភាព៖ ទី១/.ការរក្សាដើមទុន ទី២/.សន្ទនីយភាព និងទី៣/.ចំណូល។ ការណ៍នេះបញ្ជាក់ឱ្យឃើញថា ធនាគារកណ្តាលមិនអាចប្រើប្រាស់ទុនបម្រុងអន្តរជាតិយកទៅចំណាយ ឬវិនិយោគលើវិស័យ ដែលមានហានិភ័យខ្ពស់ និងមានរយៈពេលយូរបានទេ ព្រោះទុនបម្រុងអន្តរជាតិនេះត្រូវរក្សាទុកដើម្បីមានលទ្ធភាពធ្វើអន្តរាគមន៍ផ្សេងៗក្នុងទីផ្សារនិងរក្សាជំនឿទុកចិត្តក្នុងការអនុវត្តគោលនយោបាយខ្លួន ពិសេសបង្កើនទំនុកចិត្តរបស់សាធារណជនដៃគូពាណិជ្ជកម្មអន្តរជាតិ និងវិនិយោគិនជាតិនិងអន្តរជាតិមកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់ប្រទេស។

**រូបមន្តសម្រាប់គណនាទុនបម្រុងអន្តរជាតិ**

**ទុនបម្រុងដុល** = រូបិយប័ណ្ណបរទេសដែលមាននៅធនាគារជាតិនៃកម្ពុជា + មាស + ប្រាក់SDR + ទុនបម្រុងវិនិយោគក្រៅប្រទេស - ប្រាក់បញ្ញើដែលមិនតម្រូវដោយបទប្បញ្ញត្តិ (Gross Foreign Reserves = NBC cash (foreign currency) + Gold + SDR + Foreign Reserve Investment - Unrestricted Deposit (current account, settlement account))។

- រូបិយប័ណ្ណបរទេសដែលមាននៅធនាគារជាតិនៃកម្ពុជា រួមមាន រូបិប័ណ្ណបរទេសដែលជាបញ្ញើរបស់រាជរដ្ឋាភិបាល បញ្ញើរបស់គ្រឹះស្ថានហិរញ្ញវត្ថុនិងធនាគារដែលរាប់បញ្ចូលប្រាក់បម្រុងកាតព្វកិច្ចដើមទុនចុះបញ្ជីអប្បបរិមា (តម្រូវដោយបទប្បញ្ញត្តិធនាគារជាតិនៃកម្ពុជា) និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតជារូបិយប័ណ្ណបរទេស (ដូចជា មូលបត្រដែលអាចជួញដូរបាន NCDs)
- មាសដែលរាជរដ្ឋាភិបាលមានគឺជាធាតុមួយនៅក្នុងទុនបម្រុងដុល
- ប្រាក់ SDR ជាប្រាក់បម្រុងដែលបង្កើតឡើងដោយមូលនិធិរូបិយវត្ថុអន្តរជាតិ ដែលតម្រូវឱ្យប្រទេសជាសមាជិកតម្កល់ (បន្ថែមលើទុនបម្រុងដែលប្រទេសនីមួយៗមាន)
- ទុនបម្រុងវិនិយោគក្រៅប្រទេស ជាទុនបម្រុងដែលទុកសម្រាប់វិនិយោគក្រៅប្រទេស ហើយទុនបម្រុងនេះអាចបានមកពីប្រភពរូបិយបណ្ណបរទេសផ្សេងៗដែលធនាគារជាតិនៃកម្ពុជាមាន
- ប្រាក់បញ្ញើដែលមិនតម្រូវដោយបទប្បញ្ញត្តិធនាគារជាតិនៃកម្ពុជារួមមាន ប្រាក់ជារូបិយប័ណ្ណបរទេសក្នុងគណនីចរន្ត គណនីទូទាត់ ជាដើម។

**ទុនបម្រុងសុទ្ធ** = ទុនបម្រុងដុល-បំណុលបរទេស(Net Foreign Reserve = Gross Foreign Reserves -Foreign Liabilities)

- បំណុលបរទេសជាបំណុលដែលធនាគារជាតិនៃកម្ពុជាខ្ចីពីក្រៅប្រទេស កន្លងមកមានតែកម្ចីពីមូលនិធិរូបិយវត្ថុអន្តរជាតិប៉ុណ្ណោះ។

**********

# អត្រាប្តូរប្រាក់ប្រចាំខែ

| ចុងខែ | អត្រាទីផ្សារ | | | | | អត្រាផ្លូវការ | | | គម្លាតអត្រាមធ្យម | |
|---|---|---|---|---|---|---|---|---|---|---|
| | អត្រា ទិញ | អត្រា លក់ | មធ្យម | ប្រែប្រួលប្រចាំខែ | | មធ្យម | ប្រែប្រួលប្រចាំខែ | | អត្រាផ្លូវការ-ទីផ្សារ | |
| | | | | +/- | % | | +/- | % | +/- | % |
| ២០១៤ | | | | | | | | | | |
| ឧសភា | ៤.០៤៣ | ៤.០៥៣ | ៤.០៤៨ | ៣១ | 0,៧៧ | ៤.០៣២ | ១៧ | 0,៤២ | -១៦ | -0,៤0 |
| មិថុនា | ៤.០៤៧ | ៤.០៥៣ | ៤.០៥០ | ៤ | 0,១0 | ៤.០៤០ | ៨ | 0,២0 | -១0 | -0,២៥ |
| កក្កដា | ៤.០៥៤ | ៤.០៦៣ | ៤.០៥៩ | ៧ | 0,១៧ | ៤.០៥០ | ១០ | 0,២៥ | -៩ | -0,២១ |
| សីហា | ៤.០៧៤ | ៤.០៨៣ | ៤.០៧៩ | ២០ | 0,៤៩ | ៤.០៦៥ | ១៥ | 0,៣៧ | -១៤ | -0,៣៣ |
| កញ្ញា | ៤.០៨៧ | ៤.០៩៦ | ៤.០៩២ | ១៣ | 0,៣២ | ៤.០៨៥ | ២០ | 0,៤៩ | -៧ | -0,១៦ |
| តុលា | ៤.០៧៤ | ៤.០៨០ | ៤.០៧៧ | -១៣ | -0,៣២ | ៤.០៧៦ | -៩ | -0,២២ | -១ | -0,0២ |
| វិច្ឆិកា | ៤.០៥៥ | ៤.០៦២ | ៤.០៥៩ | -១៩ | -0,៤៧ | ៤.០៦៣ | -១៣ | -0,៣២ | ៥ | 0,១១ |
| ធ្នូ | ៤.០៦៤ | ៤.០៧៣ | ៤.០៦៩ | ៩ | 0,២២ | ៤.០៧៥ | ១២ | 0,៣0 | ៧ | 0,១៦ |
| ២០១៥ | | | | | | | | | | |
| មករា | ៤.០៥៩ | ៤.០៦៧ | ៤.០៦៣ | -៥ | -0,១២ | ៤.០៥០ | -២៥ | -0,៦១ | -១៣ | -0,៣២ |
| កុម្ភៈ | ៤.០៣២ | ៤.០៤០ | ៤.០៣៦ | -២៧ | -0,៦៧ | ៤.០២៧ | -២៣ | -0,៥៧ | -៩ | -0,២២ |
| មីនា | ៤.០១០ | ៤.០១៨ | ៤.០១៤ | -២២ | -0,៥៥ | ៤.០១០ | -១៧ | -0,៤២ | -៤ | -0,១0 |
| មេសា | ៤.០៦៦ | ៤.០៧៦ | ៤.០៧១ | ៥៦ | ១,៤0 | ៤.០៥០ | ៤0 | ១,00 | -២១ | -0,៥២ |
| ឧសភា | ៤.០៨៦ | ៤.០៩៦ | ៤.០៩១ | ២០ | 0,៤៩ | ៤.០៦៨ | ១៨ | 0,៤៤ | -២៣ | -0,៥៦ |
| មិថុនា | ៤.០៩៤ | ៤.១០១ | ៤.០៩៨ | ៨ | 0,២0 | ៤.០៩៨ | ៣០ | 0,៧៤ | ១ | 0,0១ |
| កក្កដា | ៤.១១៣ | ៤.១២១ | ៤.១១៧ | ១៩ | 0,៤៦ | ៤.១១៣ | ១៥ | 0,៣៧ | -៤ | -0,១0 |
| សីហា | ៤.០៩៨ | ៤.១០៥ | ៤.១០២ | -១៥ | -0,៣៦ | ៤.០៨១ | -៣២ | -0,៧៨ | -២១ | -0,៥0 |
| កញ្ញា | ៤.០៧៤ | ៤.០៨៧ | ៤.០៨១ | -២៤ | -0,៥៩ | 0.0៧៦ | -៥ | -0,១២ | -៥ | -0,១១ |
| តុលា | 0.0៤៩ | ៤.០៦០ | ៤.០៥៥ | -២៥ | -0,៦១ | ៤.០៦១ | -១៥ | -0.៣៧ | ៧ | 0,១៦ |
| វិច្ឆិកា | ៤.០៤៤ | ៤.០៥៦ | ៤.០៥០ | -៥ | -0,១២ | ៤.០៤៤ | -១៧ | -0,៤២ | -៦ | -0,១៥ |
| ធ្នូ | ៤.០៤៨ | ៤.០៥៥ | ៤.០៥២ | ៤ | 0,១0 | ៤.០៥០ | ៦ | 0,១៥ | -២ | -0,0៤ |
| ២០១៦ | | | | | | | | | | |
| មករា | ៤.០៣៧ | ៤.០៤៥ | ៤.០៤១ | -១១ | -0,២៧ | ៤.០៣៧ | -១៣ | -0,៣២ | -៤ | -0,១0 |
| កុម្ភៈ | ៤.០១០ | ៤.០១៦ | ៤.០១៣ | -២៧ | -0,៦៧ | ៤.០០៨ | -២៩ | -0,៧២ | -៥ | -0,១២ |
| មីនា | ៤.០១០ | ៤.០១៨ | ៤.០១៤ | 0 | 0,00 | ៤.០០៦ | -២ | -0,0៥ | -៨ | -0,២0 |
| មេសា | ៤.០៦១ | ៤.០៧៣ | ៤.០៦៧ | ៥១ | ១,២៧ | ៤.០៦០ | ៥៤ | ១,៣៥ | -៧ | -0,១៧ |
| ឧសភា | ៤.០៨២ | ៤.០៩១ | ៤.០៨៧ | ២១ | 0,៥២ | ៤.០៨៥ | ២៥ | 0,៦២ | -២ | -0,0៤ |
| មិថុនា | ៤.០៨១ | ៤.០៩១ | ៤.០៨៦ | -១ | -0,0២ | ៤.០៨៤ | -១ | -0,0២ | -២ | -0,0៥ |
| កក្កដា | ៤.០៩៤ | ៤.១០៣ | ៤.០៩៩ | ១៣ | 0,៣២ | ៤.០៩៧ | ១៣ | 0,៣២ | -២ | -0,0៤ |
| សីហា | ៤.០៩៦ | ៤.១០៦ | ៤.១០១ | ២ | 0,0៥ | ៤.០៩៦ | -១ | -0,0២ | -៥ | -0,១២ |
| កញ្ញា | ៤.០៨៦ | ៤.០៩៧ | ៤.០៩២ | -១១ | -0,២៧ | ៤.០៨០ | -១៦ | -0,៣៩ | -១២ | -0,២៩ |
| តុលា | ៤.០៥៣ | ៤.០៦១ | ៤.០៥៧ | -៣៣ | -0,៨១ | ៤.០៥០ | -៣0 | -0,៧៣ | -៧ | 0,១៧ |
| វិច្ឆិកា | ៤.០៣២ | ៤.០៤១ | ៤.០៣៧ | -២១ | -0,៥២ | ៤.០៣០ | -២0 | -0,៥0 | -៧ | -0,១៧ |
| ធ្នូ | ៤.០៣៩ | ៤.០៥០ | ៤.០៤៥ | ៧ | 0,១៧ | ៤.០៣៧ | ៧ | 0,១៧ | -២ | -0,0៥ |
| ២០១៧ | | | | | | | | | | |
| មករា | ៤.០៣៩ | ៤.០៥២ | ៤.០៤៦ | 00 | 0,00 | ៤.០៣៥ | -២ | -0,0៥ | -៤ | -0,១0 |
| កុម្ភៈ | ៤.០០២ | ៤.០១១ | ៤.០០៧ | -៣៧ | -0,៩២ | ៤.០០៤ | -៣១ | -0,៧៧ | ២ | 0,0៥ |
| មីនា | ៤.០០៤ | ៤.០១៣ | ៤.០០៩ | ២ | 0,0៥ | ៤.០០៥ | ១ | 0,0២ | ១ | -0,0២ |
| មេសា | ៤.០៣៩ | ៤.០៤៦ | ៤.០៤៣ | ៣៥ | 0,៨៧ | ៤.០៣៤ | ២៩ | 0,៧២ | -៩ | -0,២២ |
| ឧសភា | ៤.០៦៩ | ៤.០៧៨ | ៤.០៧៤ | ៣០ | 0,៧៤ | ៤.០៦៩ | ៣៥ | 0,៨៦ | -5 | -0,១២ |
| មិថុនា | ៤.០៨៤ | ៤.០៩២ | ៤.០៨៨ | ១៥ | 0,៣៦ | ៤.០៨៦ | ១៧ | 0,៤១ | -២ | -0,0៤ |
| កក្កដា | ៤.០៩៤ | ៤.១០២ | ៤.០៩៨ | ១០ | 0,២៤ | ៤.០៩៨ | ១២ | 0,២៩ | 0 | 0,00 |

## MONTHLY EXCHANGE RATE

| End month | Parallel Market Rate | | | | | Official Exchannge Rate | | | Spread | |
|---|---|---|---|---|---|---|---|---|---|---|
| | Purchase | Sale | Midpoint | Monthly Change | | Midpoint | Monthly Change | | Official-Market | |
| | | | | +/- | % | | +/- | % | +/- | % |
| **2014** | | | | | | | | | | |
| May | 4,043 | 4,053 | 4,048 | 31 | 0.77 | 4,032 | 17 | 0.42 | -16 | -0.40 |
| June | 4,047 | 4,053 | 4,050 | 4 | 0.10 | 4,040 | 8 | 0.20 | -10 | -0.25 |
| July | 4,054 | 4,063 | 4,059 | 7 | 0.17 | 4,050 | 10 | 0.25 | -9 | -0.21 |
| August | 4,074 | 4,083 | 4,079 | 20 | 0.49 | 4,065 | 15 | 0.37 | -14 | -0.33 |
| September | 4,087 | 4,096 | 4,092 | 13 | 0.32 | 4,085 | 20 | 0.49 | -7 | -0.16 |
| October | 4,074 | 4,080 | 4,077 | -13 | -0.32 | 4,076 | -9 | -0.22 | -1 | -0.02 |
| November | 4,055 | 4,062 | 4,059 | -19 | -0.47 | 4,063 | -13 | -0.32 | 5 | 0.11 |
| December | 4,064 | 4,073 | 4,069 | 9 | 0.22 | 4,075 | 12 | 0.30 | 7 | 0.16 |
| **2015** | | | | | | | | | | |
| January | 4,059 | 4,067 | 4,063 | -5 | -0.12 | 4,050 | -25 | -0.61 | -13 | -0.32 |
| February | 4,032 | 4,040 | 4,036 | -27 | -0.67 | 4,027 | -23 | -0.57 | -9 | -0.22 |
| March | 4,010 | 4,018 | 4,014 | -22 | -0.55 | 4,010 | -17 | -0.42 | -4 | -0.10 |
| April | 4,066 | 4,076 | 4,071 | 56 | 1.40 | 4,050 | 40 | 1.00 | -21 | -0.52 |
| May | 4,086 | 4,096 | 4,091 | 20 | 0.49 | 4,068 | 18 | 0.44 | -23 | -0.56 |
| June | 4,094 | 4,101 | 4,098 | 8 | 0.20 | 4,098 | 30 | 0.74 | 1 | 0.01 |
| July | 4,113 | 4,121 | 4,117 | 19 | 0.46 | 4,113 | 15 | 0.37 | -4 | -0.10 |
| August | 4,098 | 4,105 | 4,102 | -15 | -0.36 | 4,081 | -32 | -0.78 | -21 | -0.50 |
| September | 4,074 | 4,087 | 4,081 | -24 | -0.59 | 4,076 | -5 | -0.12 | -5 | -0.11 |
| October | 4,049 | 4,060 | 4,055 | -25 | -0.61 | 4,061 | -15 | -0.37 | 7 | 0.16 |
| November | 4,044 | 4,056 | 4,050 | -5 | -0.12 | 4,044 | -17 | -0.42 | -6 | -0.15 |
| December | 4,048 | 4,055 | 4,052 | 4 | 0.10 | 4,050 | 6 | 0.15 | -2 | -0.04 |
| **2016** | | | | | | | | | | |
| January | 4,037 | 4,045 | 4,041 | -11 | -0.27 | 4,037 | -13 | -0.32 | -4 | -0.10 |
| February | 4,010 | 4,016 | 4,013 | -27 | -0.67 | 4,008 | -29 | -0.72 | -5 | -0.12 |
| March | 4,010 | 4,018 | 4,014 | 0 | 0.00 | 4,006 | -2 | -0.05 | -8 | -0.20 |
| April | 4,061 | 4,073 | 4,067 | 51 | 1.27 | 4,060 | 54 | 1.35 | -7 | -0.17 |
| May | 4,082 | 4,091 | 4,087 | 21 | 0.52 | 4,085 | 25 | 0.62 | -2 | -0.04 |
| June | 4,081 | 4,091 | 4,086 | -1 | -0.02 | 4,084 | -1 | -0.02 | -2 | -0.05 |
| July | 4,094 | 4,103 | 4,099 | 13 | 0.32 | 4,097 | 13 | 0.32 | -2 | -0.04 |
| August | 4,096 | 4,106 | 4,101 | 2 | 0.05 | 4,096 | -1 | -0.02 | -5 | -0.12 |
| September | 4,086 | 4,097 | 4,092 | -11 | -0.27 | 4,080 | -16 | -0.39 | -12 | -0.29 |
| October | 4,053 | 4,061 | 4,057 | -33 | -0.81 | 4,050 | -30 | -0.73 | -7 | 0.17 |
| November | 4,032 | 4,041 | 4,037 | -21 | -0.52 | 4,030 | -20 | -0.50 | -7 | -0.17 |
| December | 4,039 | 4,050 | 4,045 | 7 | 0.17 | 4,037 | 7 | 0.17 | -2 | -0.05 |
| **2017** | | | | | | | | | | |
| January | 4,039 | 4,052 | 4,046 | 00 | 0.00 | 4,035 | -2 | -0.05 | -4 | -0.10 |
| February | 4,002 | 4,011 | 4,007 | -37 | -0.92 | 4,004 | -31 | -0.77 | 2 | 0.05 |
| March | 4,004 | 4,013 | 4,009 | 2 | 0.05 | 4,005 | 1 | 0.02 | 1 | -0.02 |
| April | 4,039 | 4,046 | 4,043 | 35 | 0.87 | 4,034 | 29 | 0.72 | -9 | -0.22 |
| May | 4,069 | 4,078 | 4,074 | 30 | 0.74 | 4,069 | 35 | 0.86 | -5 | -0.12 |
| June | 4,084 | 4,092 | 4,088 | 15 | -0.36 | 4,086 | 17 | 0.41 | -2 | -0.04 |
| July | 4,094 | 4,102 | 4,098 | 10 | 0.24 | 4,098 | 12 | 0.29 | 0 | 0.00 |

## តារាង: **អត្រាការប្រាក់លើប្រាក់បញ្ញើ** (ខែមិថុនា ឆ្នាំ២០១៧)

| ល.រ | ឈ្មោះធនាគារ | ប្រាក់បញ្ញើជារៀល (%) | | | | | ប្រាក់បញ្ញើជាដុល្លារអាមេរិក (%) | | | | | ប្រាក់បញ្ញើជារូបិយប័ណ្ណផ្សេងៗ (%) | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សំចៃ | មានកាលកំណត់ | | | | សំចៃ | មានកាលកំណត់ | | | | សំចៃ | មានកាលកំណត់ | | | |
| | | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | | ១ខែ | ៣ ខែ | ៦ ខែ | ១២ខែ | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ |
| 1 | អេស៊ីលីដា | ១,២៥ | ២,០០ | ៣,៥០ | ៤,២៥ | ៥,៧៥ | ០,៥០ | ០,៧៥ | ២,០០ | ៣,០០ | ៤,៧៥ | ០,០៥ | ០,០៥ | ១,០០ | ១,៥០ | ២,៥០ |
| 2 | កម្ពុជាសាធារណៈ | ០,៣៥ | ១,៥០ | ៣,០០ | ៣,៧៥ | ៤,៥០ | ០,៣៥ | ១,២៥ | ២,០០ | ៣,០០ | ៣,៧៥ | ០,៣៥ | | | | |
| 3 | កាណាឌីយ៉ា | ២,០០ | | ៥,០០ | ៦,០០ | ៧,០០ | ០,៧៥ | ២,០០ | ២,៥០ | ៣,៥០ | ៤,៧៥ | ០,២៥ | ១,០០ | ១,៥០ | ២,០០ | ២,៥០ |
| 4 | អេអិនហ្សេតរូយ៉ាល់ | | ៣,២៥ | ៣,៥០ | ៤,០០ | ៥,៥០ | ០,៥០ | ០,៣០ | ០,៥០ | ១,៥០ | ២,០០ | | | | | |
| 5 | ពាណិជ្ជកម្មក្រៅប្រទេស | ១,៥០ | ៣,០០ | ៥,០០ | ៦,០០ | ៧,០០ | ០,៧៥ | ១,៥០ | ២,៥០ | ៣,៧៥ | ៥,០០ | | | | | |
| 6 | អភិវឌ្ឍន៍និងវិនិ. | | ៣,៥០ | ៤,៦០ | ៥,៥៥ | ៦,៥០ | ០,៥០ | ២,០០ | ៣,០០ | ៤,០០ | ៥,២៥ | | | | | |
| 7 | មេយប៊ែង | | | | | | ១,៥០ | ២,៥០ | ៣,០០ | ៤,០០ | ៥,០០ | | | | | |
| 8 | ធនាគារវឌ្ឍនៈ | ០,៥០ | ១,៥០ | ២,០០ | ៣,០០ | ៣,៥០ | ០,៥០ | ១,៥០ | ២,០០ | ៣,០០ | ៣,៥០ | | | | | |
| 9 | សហពាណិជ្ជ | | | | | | ១,០០ | | ១,៥០ | ២,០០ | ២,៧៥ | | | | | |
| 10 | វឌ្ឍនៈអាស៊ី | ០,៧៥ | ៣,០០ | ៥,០០ | ៦,០០ | ៧.០០ | ០,៧៥ | ២,២៥ | ៣,២៥ | ៤,២៥ | ៥,២៥ | | | | | |
| 11 | កម្ពុជាពាណិជ្ជ | ០,៣៥ | | ១,៥០ | ១,៥០ | ១,៥០ | ១,០០ | ១,៥០ | ២,០០ | ២,២៥ | ២,៥០ | ០,៣៥ | | ១,៥០ | ១,៥០ | ១,៥០ |
| 12 | ពាណិជ្ជកម្មទី១ | | | | | | ០,៤០ | ១,២៥ | ១,៥០ | ២,០០ | ៣,០០ | | | | | |
| 13 | ក្រុងថៃមហាជន | | | | | | ០,១០ | | ០,៥០ | ០,៧៥ | ១,០០ | | | | | |
| 14 | កម្ពុជាអាស៊ី | | | | | | ២,០០ | ២,៥០ | ៣,៨០ | ៤,៨០ | ៥,៨០ | | | | | |
| 15 | មេគង្គកម្ពុជា | ៣,៧៥ | | | | | ២,០០ | | ២,៧៥ | ៣,៥០ | ៤,០០ | | | | | |
| 16 | ធនាគារកាថេ | | | | | | ០,៥០ | | ២,០០ | ២,៥០ | ៤,០០ | | | | | |
| 17 | ឥណ្ឌា | | | | | | ០,៧៥ | ១,០០ | ២,២៥ | ៣,០០ | ៤,០០ | | | | | |
| 18 | ស្ថាបនា | ២,០០ | ៤,០០ | ៥,០០ | ៥,៥០ | ៧,៥០ | ១,៥០ | ៣,៥០ | ៤,០០ | ៤,៥០ | ៦,៥០ | ១,៥០ | ៣,៥០ | ៤,០០ | ៤,៥០ | ៦,៥០ |
| 19 | ប៊ូយ៉ុងខ្មែរ | ១,០០ | ៣,០០ | ៤,០០ | ៥,០០ | ៦,០០ | ០,៥០ | ១,៥០ | ២,៥០ | ៣,០០ | ៣,៥០ | | | | | |
| 20 | ស៊ីនហានខ្មែរ | | | | | | ០,១០ | ១,២៥ | ២,២៥ | ៣,៥០ | ៤,១៥ | | | | | |
| 21 | គូកមិនកម្ពុជា | ០,៧០ | ១,៧០ | ២,៥០ | ៣,២០ | ៣,៦០ | ០,៥០ | ១,២០ | ២,០០ | ២,៧០ | ៣,១០ | | | | | |
| 22 | អ អេជ ប៊ី | ១,០០ | ៣,៥០ | ៤,០០ | ៥,០០ | ៦,០០ | ១,០០ | ២,០០ | ២,៥០ | ៣,៥០ | ៤,៧៥ | | | | | |
| 23 | ហ្វីលិប | | | | | | ១,០០ | ២,២៥ | ២,៧៥ | ៣,៥០ | ៥,០០ | | | | | |
| 24 | ភ្នំពេញ ពាណិជ្ជ | ១,២៥ | | | | | ២,០០ | ១,០០ | ៣,២៥ | ៤,២៥ | ៥,៥០ | | | | | |
| 25 | សាខម | ០,៥០ | ៣,០០ | ៤,៥០ | ៥,០០ | ៦,២៥ | ០,៥០ | ២,៥០ | ៣,៥០ | ៤,០០ | ៥,២៥ | | | | | |
| 26 | ស៊ីអាយអិមប៊ី | | | | | | ១,៥០ | ១,៥០ | ២,២៥ | ៣,២៥ | ៤,០០ | | ២,៥០ | ៣,៥០ | ៤,២៥ | ៥,០០ |
